# អង្គការសហប្រជាជាតិ

# សេចក្តីពន្យល់ទូទៅលេខ៣២

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

## មាត្រា១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស

នាសម័យប្រជុំលើកទី១៩ ខែកក្កដា ឆ្នាំ២០០៧

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

# អង្គការសហប្រជាជាតិ

## សេចក្តីពន្យល់ទូទៅលេខ៣២

## កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ

*មាត្រា១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

អនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស

នាសម័យប្រជុំលើកទី១៩ ខែកក្កដា ឆ្នាំ២០០៧

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

ខែមីនា ឆ្នាំ២០១៣

# មាតិការឿង

ទំព័រ

សេចក្ដីផ្ដើម..........................................................................៥

មាត្រា១៤..............................................................................១២

I- កំណត់សំគាល់ទូទៅ.........................................................១៥

II- ស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្ដី........២០

III- សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្ដីមួយមានសមត្ថកិច្ច ឯករាជ្យ និងអនាគតិ..................២៦

IV- សច្ចធារណ៍នៃនិរទោស........................................................៤៣

V- សិទ្ធិរបស់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ................៤៥

VI- អនីតិជន............................................................................៥៨

VII- ការពិនិត្យឡើងវិញដោយសាលាក្ដីជាន់ខ្ពស់.................៦០

VIII- សំណងជំងឺចិត្តក្នុងករណីយុត្តិនិសេធ.........................៦៦

IX- ទ្វេទណ្ឌភាព........................................................................៦៨

X- ទំនាក់ទំនងរវាងមាត្រា១៤ ជាមួយនឹងបទប្បញ្ញត្តិផ្សេងៗទៀតនៃកតិកាសញ្ញានេះ.....................................................................៧១

# សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាលពីឆ្នាំ១៩៩២។ កតិកាសញ្ញានេះ ការពារសិទ្ធិសំខាន់ៗជាច្រើន។ ក្នុងចំណោមសិទ្ធិទាំងនោះ គឺមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្ដី និងសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុងមាត្រា១៤។

គណៈកម្មាធិការសិទ្ធិមនុស្ស គឺជាគណៈកម្មាធិការមួយដែលមានសមាជិក១៨រូប ជាអ្នកជំនាញការឯករាជ្យ បោះឆ្នោតជ្រើសតាំងដោយរដ្ឋភាគីដើម្បីតាមឃ្លាំមើលការអនុវត្តកតិកាសញ្ញានេះ។ គណៈកម្មាធិការពិនិត្យមើលរបាយការណ៍ដែលរដ្ឋភាគីបានដាក់ជូនទៀងទាត់ តាមកាលកំណត់។ រួចហើយ គណៈកម្មាធិការអនុម័តសេចក្ដីសង្កេតសន្និដ្ឋានលើរបាយការណ៍នោះ ដែលចាត់ទុកជាអនុសាសន៍របស់គណៈកម្មាធិការចំពោះរដ្ឋភាគី អំពីរបៀបធ្វើឲ្យប្រសើរដល់ការគោរពតាមកាតព្វកិច្ចរបស់រដ្ឋភាគីនោះចំពោះកតិកាសញ្ញា។ ចំពោះរដ្ឋភាគីណា ដែលបានផ្ដល់សច្ចាប័នលើពិធីសារបន្ថែមទី១នៃកតិកាសញ្ញានេះដែរ គណៈកម្មាធិការនឹងមានសិទ្ធិពិនិត្យមើលបណ្ដឹងដែលប្ដឹងដោយបុគ្គលនានា ឬក្រុម ដែលបានចោទថាមានការបំពានលើសិទ្ធិរបស់ពួកគេ ដោយរដ្ឋភាគី។ វា

មានសារៈសំខាន់ណាស់ដែលរដ្ឋភាគី ត្រូវយល់ពីទំហំនៃកាតព្វកិច្ចរបស់គេក្រោមកតិកាសញ្ញានេះ។ ដើម្បីជួយដល់រដ្ឋភាគីលើករណីនេះ គណៈកម្មាធិការអនុម័តសេចក្តីពន្យល់ទូទៅ ដែលពន្យល់ពិស្តារម្តងមួយមាត្រាៗពីកាតព្វកិច្ចរបស់រដ្ឋភាគីក្រោមកតិកាសញ្ញានេះ។ សេចក្តីពន្យល់ទូទៅទាំងនេះ ធ្វើឡើងដោយឈរលើមូលដ្ឋាននៃសេចក្តីសង្កេតសន្និដ្ឋានកន្លងមក និងសេចក្តីសំរេចរបស់គណៈកម្មាធិការ លើរឿងក្តីនីមួយៗ ដែលបុគ្គលបានប្តឹងមក។

សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ គឺមានសារៈសំខាន់ដល់កិច្ចការពារនីតិរដ្ឋនៅក្នុងប្រទេសណាក៏ដោយ។ ហេតុនេះហើយបានជាគណៈកម្មាធិការសិទ្ធិមនុស្ស បានអនុម័តសេចក្តីពន្យល់ទូទៅលេខ៣២ ស្តីពីមាត្រា១៤ កាលពីខែកក្កដា ឆ្នាំ២០០៧ ដើម្បីផ្តល់ការណែនាំបន្ថែមទៀតថាតើសិទ្ធិដ៏ស្មុគស្មាញនេះ ជាក់ស្តែងពាក់ព័ន្ធនឹងអ្វីខ្លះទៅ។ គណៈកម្មាធិការ បានសង្កត់ធ្ងន់ថា រាល់កិច្ចធានាការពារមានចែងក្នុងមាត្រា១៤ ត្រូវយកមកអនុវត្តនៅគ្រប់រដ្ឋភាគី ដោយមិនគិតថារដ្ឋនោះដើរតាមប្រព័ន្ធច្បាប់បារាំង ឬប្រព័ន្ធច្បាប់អង់គ្លេសឡើយ។

នៅក្នុងសេចក្តីពន្យល់ទូទៅនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានពន្យល់ពិស្តារពីកិច្ចការពារផ្សេងៗនៃដំណើរនីតិវិធីត្រឹមត្រូវដូចមានចែងក្នុងមាត្រា១៤។ ដោយចាប់ផ្តើមពីសិទ្ធិស្មើភាពគ្នា

នៅចំពោះមុខតុលាការ និងសាលាជម្រះក្តី គណៈកម្មាធិការសិទ្ធិមនុស្ស បានគូសបញ្ជាក់ថា កិច្ចការពារទូទៅនេះ ត្រូវយកមកអនុវត្ត មិនត្រឹមតែនៅក្នុងប្រព័ន្ធតុលាការនោះទេ តែក៏ត្រូវអនុវត្តផងដែរនៅក្នុងដំណើរការយុត្តិធម៌ទាំងអស់ ដូចជា តួយ៉ាង នីតិវិធីដាក់វិន័យមន្ត្រីរាជការសាធារណៈជាដើម។ គណៈកម្មាធិការ ក៏បានសង្កត់ធ្ងន់ពីសិទ្ធិទទួលបានសេវាយុត្តិធម៌ដោយស្មើភាពគ្នា។ ទោះបីយ៉ាងណាក៏ដោយ សិទ្ធិទទួលបានសេវាយុត្តិធម៌ដល់ជនក្រីក្រជារឿយៗ ត្រូវបានរារាំងដោយការខ្វះជំនួយផ្នែកច្បាប់។ ការផ្តល់ជំនួយផ្នែកច្បាប់ដោយមិនគិតថ្លៃដល់ជនក្រីក្រ គួរត្រូវធានាថា ជនក្រីក្រមានសិទ្ធិទទួលបានសេវាយុត្តិធម៌កាន់តែប្រសើរ។

គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់ការពន្យល់យ៉ាងក្បោះក្បាយអំពីសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង។ គណៈកម្មាធិការ បានសង្កត់ធ្ងន់ជាពិសេសពីឯករាជភាពរបស់ចៅក្រម ដែលត្រូវធានាការពារតាមរយៈ ជាតួយ៉ាង វិធីនៃការតែងតាំង សន្តិសុខនៃមុខតំណែង វិធាននៃការតំឡើងស័ក្តិ ការផ្ទេរ ការព្យួរ និងការចូលនិវត្តន៍។ វាជាអាណត្តិដាច់ខាតដែលចៅក្រមត្រូវរួចផុតពីការជ្រៀតជ្រែកខាងនយោបាយ ពីអំណាចនីតិប្រតិបត្តិ។ កិច្ចធានាការពារដើម្បីរក្សាឯករាជភាពរបស់ចៅក្រម គួរត្រូវបានតម្កល់នៅក្នុងច្បាប់។

នៅក្នុងសេចក្តីពន្យល់ទូទៅនេះ គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានពន្យល់ផងដែរពីគោលការណ៍អនាគតិ។ ទស្សនៈនៃឯករាជភាពរបស់ចៅក្រម សំដៅដល់សមត្ថភាពរបស់ចៅក្រម ក្នុងការធ្វើសេចក្តីសម្រេចដោយសេរី រួចផុតពីទម្រង់ណាមួយនៃឥទ្ធិពលនយោបាយ រីឯទស្សនៈនៃអនាគតិ សំដៅដល់សមត្ថភាពរបស់ចៅក្រម មិនត្រូវទទួលឥទ្ធិពលដោយមានភាពលំអៀង ឬការរើសអើសផ្ទាល់ខ្លួន ឬដោយបុរេនិច្ឆ័យណាមួយ អំពីរឿងក្តីនៅចំពោះមុខខ្លួននោះទេ ហើយមិនត្រូវលំអៀងទៅរកភាគីណាមួយនៃរឿងក្តីឡើយ។ ចៅក្រមមិនត្រឹមតែមិនលំអៀងនោះទេ ក៏ប៉ុន្តែគាត់ត្រូវបង្ហាញឲ្យគេឃើញថា គាត់ពិតជាមិនលំអៀងមែន។

គណៈកម្មាធិការសិទ្ធិមនុស្ស បានពន្យល់ថា សវនាការដោយយុត្តិធម៌ គួរត្រូវបានរៀបចំឲ្យបានរហ័សនិងជាសាធារណៈ។ នៅពេលដែលបុគ្គលម្នាក់ត្រូវជាប់ចោទពីបទព្រហ្មទណ្ឌ មាត្រា១៤ ធានាការពារគោលការណ៍សច្ចធារណ៍។ គោលការណ៍នេះ ត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្ស ចាត់ទុកថាជាគោលការណ៍គ្រឹះក្នុងការការពារសិទ្ធិមនុស្ស ដាក់បន្ទុកទៅលើព្រះរាជអាជ្ញាក្នុងការបង្ហាញភស្តុតាងពីការចោទប្រកាន់របស់ខ្លួនឲ្យហួសពីវិមតិសង្ស័យ។ ហេតុដូច្នេះ គឺមិនមែនជនជាប់ចោទ ជាអ្នកត្រូវបង្ហាញភស្តុតាងថាគាត់ជាជនគ្មានកំហុសនោះទេ។

គ្រប់ជនជាប់ចោទពីបទព្រហ្មទណ្ឌគួរទទួលបានប្រយោជន៍ពីការការពារមួយចំនួន ដូចជាសិទ្ធិត្រូវដឹងភ្លាមៗពីការចោទប្រកាន់នឹងខ្លួន សិទ្ធិទទួលបានមេធាវីតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដោយមិនបង់ថ្លៃ នៅក្នុងរឿងក្ដីមួយចំនួន និងសិទ្ធិទទួលបានសមភាពនៃភាគីក្នុងរឿងក្ដី រវាងការការពារ និងការចោទប្រកាន់។ មាត្រា១៤ ក៏ការពារមិនឲ្យមានការឆ្លើយសារភាពដោយបង្ខំដែរ។ កិច្ចការពារខ្លះក្នុងចំណោមកិច្ចការពារទាំងនេះ ក៏មានចែងនៅក្នុងមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សេចក្ដីពន្យល់ទូទៅលេខ៣២ ពន្លាតគោលការណ៍ជាមូលដ្ឋាននេះ ដល់យុត្តិធម៌អនីតិជនដែរ។ ជាការពិតណាស់ អនីតិជនក៏គួរទទួលបានកិច្ចការពារដូចគ្នា ដូចមនុស្សពេញវ័យដែរ។ បន្ថែមពីនេះ អនីតិជនគួរមានកិច្ចការពារពិសេស។ គណៈកម្មាធិការសិទ្ធិមនុស្សបានសង្កត់ធ្ងន់ថា ការឃុំខ្លួនអនីតិជន មុនពេលសវនាការ និងនៅពេលសវនាការ គួរតែចៀសវាងឲ្យបានច្រើនបំផុតតាមតែអាចធ្វើបាន។ ជាទូទៅ រដ្ឋគួរស្វះស្វែងបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជនឲ្យបានត្រឹមត្រូវមួយ។ ក្នុងករណីនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែចាត់ទុកការអនុម័តច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ថាជាជំហានដំបូងមួយ ឆ្ពោះទៅរកការបង្កើតប្រព័ន្ធមួយបែបនេះ។

សេចក្ដីពន្យល់ទូទៅលេខ៣២នេះក៏មាននិយាយពីសិទ្ធិប្ដឹងឧទ្ធរណ៍ និងសិទ្ធិទទួលសំណងពីយុត្តិនិសេធ។ សេចក្ដីពន្យល់នេះរំលឹកឡើងវិញពីគោលការណ៍ទ្វេទណ្ឌភាព ដែលហាមមិនឲ្យជនណាមួយត្រូវបានកាត់ទោស និងផ្ដន្ទាទោសពីរដងចំពោះបទល្មើសដដែល។

ជាទីបញ្ចប់ សេចក្ដីពន្យល់ទូទៅលេខ៣២នេះ បានផ្ដល់នូវចំណុចសំខាន់ៗមួយចំនួនគួរឲ្យចងចាំ អំពីទំនាក់ទំនងរវាងមាត្រា១៤ និងបទប្បញ្ញត្តិដទៃទៀតនៃកតិកាសញ្ញា។ ជាពិសេស សេចក្ដីពន្យល់នេះ រំលឹកថា ចំលើយសារភាពដោយបង្ខំគឺជាការបំពាននឹងមាត្រា១៤ និងមាត្រា១៧ អំពីការហាមប្រាមទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក។ ការពន្យារពេលសវនាការដោយមិនត្រឹមត្រូវ គឺមិនត្រឹមតែបំពានលើសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌នោះទេ តែថែមទាំងបំពានលើមាត្រា៩(៣) ដែលចែងថាបុគ្គលទាំងឡាយណាដែលត្រូវបានចាប់ខ្លួន ឃុំខ្លួន ដោយជាប់ចោទពីបទព្រហ្មទណ្ឌមួយ ត្រូវមានសិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្រប បើមិនដូច្នេះទេ ត្រូវតែដោះលែង។ គណៈកម្មាធិការសិទ្ធិមនុស្ស ក៏បានពន្យល់ថា វិធីដែលដំណើរការរឿងក្ដីព្រហ្មទណ្ឌ អាចប៉ះពាល់ដល់ការអនុវត្ត និងការទទួលបានសិទ្ធិដទៃទៀត ដែលត្រូវបានការពារដោយកតិកាសញ្ញានេះ។ គណៈកម្មាធិការផ្ដល់ឧទាហរណ៍ពីបទបរិហារ

កេរ្តិ៍ ដែលត្រូវបានគេទុកមិនចាត់ការអស់ជាច្រើនឆ្នាំ ហើយពន្យល់ថា ការពន្យារពេលនេះ មានផលប៉ះពាល់យ៉ាងខ្លាំងដល់ជនត្រូវចោទ ហើយអាចរិតត្បិតមិនត្រឹមត្រូវដល់សិទ្ធិមានសេរីភាពនៃការបញ្ចេញមតិរបស់គាត់ ដែលត្រូវបានការពារតាមមាត្រា១៩ នៃកតិកាសញ្ញា។

សរុបសេចក្តីមក សេចក្តីពន្យល់ទូទៅលេខ៣២នេះ មានសារប្រយោជន៍ជាពិសេស ដោយចាត់ទុកថា មាត្រា១៤ គឺជាបទប្បញ្ញត្តិមួយស្មុគស្មាញ។ នៅក្នុងឯកសារដ៏សំខាន់នេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានផ្តល់នូវការណែនាំយ៉ាងក្បោះក្បាយពីវិធិបកស្រាយមាត្រា១៤ - ប្រការនេះគួរតែជាប្រយោជន៍ដល់អ្នកប្រតិបត្តិទាំងឡាយណា ដែលមានការប្តេជ្ញាខ្ពស់ ដល់ការអនុវត្តសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌នៅកម្ពុជា។

ការិយាល័យឧត្តមស្នងការ

អង្គការសហប្រជាជាតិ

ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

ខែមិថុនា ឆ្នាំ២០១៣

## មាត្រា ១៤

១. ជនគ្រប់រូប ត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី ។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជំរះរឿងក្តីរបស់ខ្លួនដោយយុត្តិធម៌ និងជាសាធារណៈ ក្នុងការសម្រេចសេចក្តីលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងរឿងក្តីព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ចក្នុងរឿងក្តីរដ្ឋប្បវេណី។ សារព័ត៌មាន និងសាធារណៈជនអាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ ដោយសារមូលហេតុសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ ក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុតតាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេស ដែលថាការធ្វើជាសាធារណៈ នឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌។ ប៉ុន្តែ ការចេញសាលក្រមទាំងអស់ ក្នុងរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីទាក់ទងនឹងទំនាស់មាតុភាព ឬអាណាព្យាបាលភាពរបស់កុមារ ។

២. ជនណាដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសន្មត់ជាមុនថាជាជនគ្មានទោស រហូតដល់ត្រូវបានបង្ហាញពីពិរុទ្ធភាព ស្របតាមច្បាប់។

៣. ក្នុងការសម្រេចសេចក្តី លើការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានការធានាការពារជាអប្បបរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោមៈ

(ក) ត្រូវបានប្រាប់ភ្លាមៗ និងដោយលំអិត អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ ។

(ខ) ត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីតាមការជ្រើសរើសរបស់ខ្លួន។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួសហេតុ ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់ផ្ដល់ឱ្យខ្លួន ក្នុងករណីណាក៏ដោយដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃ នៅក្នុងករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេនោះ ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយសាក្សីដាក់បន្ទុក និងទទួលបានការចូលរួមពី និងការសួរចម្លើយសាក្សីដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ ។

(ច) ត្រូវទទួលបានអ្នកបកប្រែភាសាដោយឥតគិតថ្លៃ បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់នៅតុលាការ ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំ ឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ ។

៤. នៅក្នុងករណីអនីតិជន នីតិវិធីត្រូវយកចិត្តទុកដាក់ទៅលើអាយុរបស់ពួកគេ និងសេចក្តីត្រូវការក្នុងការលើកស្ទួយការស្តារនិតិសម្បទាពួកគេឡើងវិញ ។

៥. ជនគ្រប់រូបដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីមួយខ្ពស់ជាង ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញស្របតាមច្បាប់ ។

៦. នៅពេលជនណាម្នាក់ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌដោយសេចក្តីសំរេចស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថាអង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថាការផ្តន្ទាទោសនេះមានយុត្តិនិសេធ ជនដែលទទួលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងស្របតាមច្បាប់ លើកលែងតែមានការបង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេល បណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក ។

៧. គ្មានជនណាម្នាក់ត្រូវយកមកកាត់ទោស ឬយកមកផ្តន្ទាទោសម្តងទៀតចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងចោទរួចហើយ ស្របតាមច្បាប់ និងនិតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗនោះឡើយ ។

## សេចក្ដីពន្យល់ទូទៅលេខ៣២
## កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
*មាត្រា១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌*

### I-កំណត់សំគាល់ទូទៅ

១. សេចក្ដីពន្យល់ទូទៅនេះជំនួសឲ្យសេចក្ដីពន្យល់ទូទៅលេខ១៣ (សម័យប្រជុំលើកទី២១)។

២. សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការនិងសាលាជម្រះក្ដី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាធាតុផ្សំដ៏សំខាន់មួយនៃការការពារសិទ្ធិមនុស្ស និងប្រើជាមធ្យោបាយតាមនីតិវិធី ដើម្បីធានាការពារដល់នីតិរដ្ឋ។ មាត្រា១៤ នៃកតិកាសញ្ញានេះ មានគោលដៅធានាដល់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវ និងដើម្បីសម្រេចបានគោលដៅនេះ ត្រូវធានាការពារដល់សិទ្ធិជាក់លាក់មួយចំនួន។

៣. មាត្រា១៤ មានលក្ខណៈស្មុគស្មាញដោយឡែកមួយ ដោយរួមបញ្ចូលនូវកិច្ចធានាការពារផ្សេងៗ ក្រោមវិសាលភាពនៃការអនុវត្តខុសៗគ្នា។ ឃ្លាទី១ នៃកថាខ័ណ្ឌទី១ ចែងពីកិច្ចធានាការពារជាទូទៅនៃភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្ដី

ដោយមិនគិតពីលក្ខណៈចរិតនៃនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះទាំងនេះឡើយ។ ឃ្លាទី២ នៃកថាខ័ណ្ឌដដែល ផ្តល់សិទ្ធិឲ្យបុគ្គលគ្រប់រូប ទទួលបានសវនាការជាសាធារណៈ និងយុត្តិធម៌ពីសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ និងមិនលំអៀង ហើយដែលត្រូវបានបង្កើតឡើងដោយច្បាប់ ប្រសិនបើបុគ្គលនោះ ប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ឬប្រសិនបើសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលនោះ ត្រូវបានសម្រេចដោយបណ្តឹងតាមផ្លូវតុលាការ។ ក្នុងនីតិវិធីបែបនេះ សាធារណជន និងប្រព័ន្ធសារព័ត៌មានអាចមិនត្រូវបានអនុញ្ញាតឱ្យចូលស្តាប់សវនាការ តែក្នុងករណីនានាដែលបានបញ្ជាក់ក្នុងល្បះទី៣នៃ កថាខ័ណ្ឌទី១ តែប៉ុណ្ណោះ។ កថាខ័ណ្ឌទី២ ដល់ទី៥ នៃមាត្រានេះ មានចែងពីកិច្ចការពារតាមនីតិវិធីសំរាប់ជនដែលត្រូវចោទពីបទល្មើសព្រហ្មទណ្ឌ។ កថាខ័ណ្ឌទី៦ មានចែងពីសិទ្ធិដ៏សំខាន់មួយ ក្នុងការទទួលបានសំណងសមរម្យ ក្នុងករណីយុត្តិនិសេធក្នុងរឿងក្តីព្រហ្មទណ្ឌ។ កថាខ័ណ្ឌទី៧ ហាមឃាត់*ទ្វេទណ្ឌភាព* ហេតុដូច្នេះហើយ កថាខ័ណ្ឌនេះ ធានាការពារសេរីភាពជាសារវន្ត ពោលគឺសិទ្ធិរួចផុតពីការជំនុំជម្រះ ឬការផ្តន្ទាទោសម្តងទៀត ចំពោះបទល្មើសមួយដែលបុគ្គលនេះ ត្រូវបានផ្តន្ទាទោស ឬសម្រេចឲ្យរួចពីការចោទប្រកាន់ជាស្ថាពរហើយនោះ។ នៅក្នុងរបាយការណ៍របស់ខ្លួន រដ្ឋភាគីនៃកតិកាសញ្ញា គួរតែបែងចែងឲ្យច្បាស់លាស់ រវាងទិដ្ឋភាពផ្សេងៗទាំងនេះ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

៤. មាត្រា១៤ មានចែងពីកិច្ចធានាការពារនានា ដែលរដ្ឋភាគីត្រូវតែគោរពតាមដោយមិនគិតពីប្រពៃណីគតិយុត្ត និងច្បាប់ជាតិរបស់រដ្ឋភាគីនោះឡើយ។ នៅពេលដែលរដ្ឋភាគីធ្វើរបាយការណ៍អំពីវិធីអនុវត្តកិច្ចធានាការពារទាំងនេះ ឱ្យស្របតាមប្រព័ន្ធគតិយុត្តរបស់ខ្លួន គណៈកម្មាធិការក៏ធ្វើការកត់សំគាល់ថា ច្បាប់ជាតិមិនអាចមានឆន្ទានុសិទ្ធិដាច់មុខ ក្នុងការកំណត់ខ្លឹមសារជាសារវន្ត នៃកិច្ចធានាការពារតាមកតិកាសញ្ញានេះឡើយ។

៥. ទោះបីជាការដាក់ខលក្ខខណ្ឌលើប្រការមួយចំនួននៃមាត្រា១៤ អាចទទួលយកបានក៏ដោយ ក៏ការដាក់ខលក្ខខណ្ឌជាទូទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នឹងមានវិសមិតភាពជាមួយកម្មវត្ថុ និងគោលបំណងនៃកតិកាសញ្ញានេះ។[១]

៦. ទោះបីជាមាត្រា១៤ មិនត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃសិទ្ធិនានាដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន តាមមាត្រា៤ កថាខ័ណ្ឌទី២ នៃកតិកាសញ្ញានេះក៏ដោយ ក៏រដ្ឋនានាដែលកំពុងធ្វើបដិប្បញ្ញត្តិពីនីតិវិធីធម្មតា ដែលតំរូវតាមមាត្រា១៤ នៅក្នុងកាលៈទេសៈនៃគ្រាអាសន្នជាសាធារណៈ គួរតែធានាថា បដិប្បញ្ញត្តិបែបនេះ ក៏ពុំជ្រុល

[១] សេចក្តីពន្យល់ទូទៅលេខ២៤ (១៩៩៤) ស្តីពីបញ្ហានានាទាក់ទងនឹងការដាក់ខលក្ខខណ្ឌ បន្ទាប់ពីការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃកតិកាសញ្ញា ឬពិធីសារបន្ថែមនៃកតិកាសញ្ញា ឬទាក់ទងនឹងសេចក្តីប្រកាស ក្រោមមាត្រា៤១ នៃកតិកាសញ្ញានេះ ត្រង់កថាខណ្ឌទី៨។

ហួសពីស្ថានតំរូវយ៉ាងតឹងរឹង តាមសភាពការណ៍ជាក់ស្តែងនោះឡើយ។ កិច្ចធានាការពារនានានៃការជម្រះក្តីដោយយុត្តិធម៌ពុំអាចដាក់ឲ្យស្ថិតក្រោមវិធានការនៃបដិប្បញ្ញត្តិ ដែលអាចនឹងធ្វើឲ្យអន្តរាយដល់ការការពារសិទ្ធិ ដែលមិនអាចធ្វើបដិប្បញ្ញត្តិបាននោះឡើយ។ អាស្រ័យហេតុនេះ តួយ៉ាងដូចជាមាត្រា៦ ទាំងមូល នៃកតិកាសញ្ញានេះ គឺមិនអាចធ្វើបដិប្បញ្ញត្តិបានឡើយ។ នេះមានន័យថា សវនាការណាក៏ដោយ ដែលនាំទៅដល់ការដាក់ទោសប្រហារជីវិត នៅកំឡុងរដ្ឋមានគ្រាអាសន្ន ត្រូវតែអនុលោមតាមប្បញ្ញត្តិនានានៃមាត្រានេះ ដោយរួមបញ្ចូលរាល់លក្ខខណ្ឌតំរូវនៃមាត្រា១៤ ផង។[២] ដូចគ្នានេះដែរ ដូចជាមាត្រា៧ ទាំងស្រុង ក៏មិនអាចធ្វើបដិប្បញ្ញត្តិបានផងដែរ មានន័យថា ជាគោលការណ៍ពុំមានកំណត់ហេតុយកចម្លើយ ឬចម្លើយសារភាព ឬភស្តុតាងផ្សេងទៀតដែលទទួលបានដោយរំលោភបំពាននឹងប្បញ្ញត្តិនៃមាត្រានេះ អាចយកមកប្រើជាភស្តុតាង នៅក្នុងរឿងក្តីណាមួយ ដែលស្ថិតនៅក្រោមមាត្រា១៤ នោះឡើយ រួមទាំងក្នុងពេលប្រទេសមានគ្រាអាសន្ន[៣] លើកលែងតែក្នុងករណីដែលកំណត់ហេតុយកចម្លើយឬ

[២] សេចក្តីពន្យល់ទូទៅលេខ២៩ (២០០១) លើមាត្រា៤៖ បដិប្បញ្ញត្តិនៅកំឡុងរដ្ឋមានគ្រាអាសន្ន ត្រង់កថាខណ្ឌទី១៥។

[៣] សេចក្តីពន្យល់ទូទៅលេខ២៩ (២០០១) លើមាត្រា៤៖ បដិប្បញ្ញត្តិនៅកំឡុងរដ្ឋមានគ្រាអាសន្ន ត្រង់កថាខណ្ឌទី៧ និងទី១៥។

ចម្លើយសារភាព ដែលទទួលបានដោយបំពានលើមាត្រា៧ នោះត្រូវបានយកទៅប្រើប្រាស់ ជាភស្តុតាងថាទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីដទៃទៀត ដែលត្រូវបានហាមឃាត់ដោយបទប្បញ្ញត្តិនេះ បានកើតមានឡើង។[៤] ការអនុវត្តខុសពីគោលការណ៍គ្រឹះនានា នៃការជម្រះក្តីដោយយុត្តិធម៌ រួមទាំងសច្ចធារណ៍នៃនិរទោសត្រូវហាមឃាត់គ្រប់ពេលវេលា។[៥]

---

[៤] សូមមើលអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ត្រង់មាត្រា១៥។

[៥] សេចក្តីពន្យល់ទូទៅលេខ២៩ (២០០១) លើមាត្រា៤៖ បដិប្បញ្ញត្តិនៅកំឡុងគ្រាអាសន្នរបស់រដ្ឋ ត្រង់កថាខណ្ឌទី១១។

## II. ស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី

**៧**. វាក្យខណ្ឌទី១នៃមាត្រា១៤ កថាខណ្ឌទី១ធានាការពារជាទូទៅនូវសិទ្ធិស្មើភាពគ្នា នៅចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ការធានាការពារនេះ ពុំគ្រាន់តែអនុវត្តចំពោះតុលាការ និងសាលាជម្រះក្តីនានា ដែលមានចែងនៅក្នុងវាក្យខណ្ឌទី២ នៃកថាខណ្ឌនេះ នៃមាត្រា១៤ នោះទេ ប៉ុន្តែក៏ត្រូវយកមកអនុវត្តផងដែរ នៅពេលណាដែលច្បាប់ជាតិ ប្រគល់តួនាទីយុត្តាធិការ ឲ្យដល់ស្ថាប័នយុត្តាធិការណាមួយ ធ្វើការជំនុំជម្រះក្តី។[៦]

**៨**. ក្នុងន័យទូទៅ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី ធានាការពារជាបន្ថែមទៀតលើគោលការណ៍នានាដែលមានចែងក្នុងវាក្យខណ្ឌទី២នៃមាត្រា១៤ កថាខណ្ឌទី១ពីសិទ្ធិទទួលបាន*ដោយសមភាព* និងសិទ្ធិស្មើគ្នានៃភាគីក្នុងរឿងក្តី ព្រមទាំងធានាថា ភាគីនានាក្នុងដំណើរការនីតិវិធី ត្រូវបានប្រព្រឹត្តលើដោយគ្មានការរើសអើងណាមួយឡើយ។

**៩**. មាត្រា១៤ ក្តោបនូវសិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការនៅក្នុងរឿងក្តីនានាដែលមានការសម្រេចសេចក្តីពីបទចោទប្រកាន់ព្រហ្មទណ្ឌ ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចនានា នៅក្នុងបណ្តឹងតាម

---

[៦] *បណ្តឹងលេខ១០១៥/២០០១ រវាងPerterer និងប្រទេសអូទ្រីស កថាខណ្ឌទី៩.២ (នីតិវិធីរឿងក្តីទណ្ឌកម្មខាងវិន័យ ប្រឆាំងនឹងមន្ត្រីសាធារណៈ) បណ្តឹងលេខ ៩៦១/២០០០ រវាងEverett និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៦.៤ (ស្តីពីការធ្វើបត្យាប័ន)។*

ផ្លូវតុលាការ។ សិទ្ធិទទួលបានសេវាកម្មពីរដ្ឋបាលយុត្តិធម៌ ត្រូវតែធានាការពារប្រកបដោយប្រសិទ្ធភាព នៅក្នុងរឿងក្តីបែបនេះទាំងអស់ ដើម្បីធានាថា តាមន័យនីតិវិធី ពុំមានបុគ្គលណាម្នាក់ត្រូវបានដកហូតសិទ្ធិក្នុងការទាមទាររកយុត្តិធម៌ឡើយ។ សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការ និងសាលាជម្រះក្តី ព្រមទាំងសិទ្ធិស្មើភាពគ្នានៅចំពោះមុខស្ថាប័នទាំងនោះ មិនត្រូវកំរិតត្រឹមតែពលរដ្ឋនៃរដ្ឋភាគីនោះទេ ប៉ុន្តែត្រូវតែផ្តល់ឲ្យបុគ្គលគ្រប់រូប ដោយមិនគិតពីសញ្ជាតិ ឬនិបេតិកជន ឬឋានៈអ្វីផ្សេងទៀតក៏ដោយរបស់ពួកគេនោះទេ ទោះបីជាជនស្វែងរកសិទ្ធិជ្រកកោន ជនភៀសខ្លួន ពលករទេសន្តរប្រវេសន៍ កុមារគ្មានអាណាព្យាបាល ឬបុគ្គលផ្សេងទៀតដែលចូលទៅក្នុងដែនដី ឬស្ថិតក្រោមយុត្តាធិការនៃរដ្ឋភាគីនោះ។ ស្ថានភាពមួយដែលការប៉ុនប៉ងរបស់បុគ្គលម្នាក់ ដើម្បីទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការ ឬសាលាជម្រះក្តីដែលមានសមត្ថកិច្ចត្រូវបានបដិសេធជាប្រព័ន្ធតាមព្រឹត្តន័យ ឬតាមព្រឹត្តហេតុ គឺជាការអនុវត្តផ្ទុយនឹងការធានាការពារតាមមាត្រា១៤ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី១។[៧] ការធានាការពារនេះ ក៏ហាមឃាត់ផងដែរ នូវការបែងចែកណាមួយអំពីសិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ ពីតុលាការ និងសាលាជម្រះក្តីនានា ដោយគ្មានមូលដ្ឋានច្បាប់ និងមិនអាចធ្វើយុត្តិកម្មបានដោយមូលដ្ឋានសត្យានុម័ត និងសមហេតុផលនានា។

[៧] បណ្តឹងលេខ៤៦៨/១៩៩១ រវាងOló Bahamonde និងប្រទេសអេក្វាទ័រហ្គីណេ កថាខ័ណ្ឌទី៩.៤

ជាការរំលោភបំពានលើការធានាការពារនេះ ប្រសិនបើបុគ្គលមួយចំនួន ត្រូវបានរារាំងមិនឲ្យដាក់បណ្តឹងប្រឆាំងនឹងបុគ្គលណាមួយផ្សេងទៀត ដោយសំអាងលើហេតុផលពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗ ដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិ ឋានៈពីកំណើត ឬឋានៈផ្សេងៗទៀត។[៨]

១០. ការទទួលបាន ឬមិនទទួលបានជំនួយផ្លូវច្បាប់ ជានិច្ចកាលកំណត់ថាតើបុគ្គលម្នាក់ អាចទទួលបាននីតិវិធីរឿងក្តីពាក់ព័ន្ធនានា ឬអាចចូលរួមនៅក្នុងនីតិវិធីទាំងនេះ បានប្រកបដោយអត្ថន័យ។ ទោះបីជាមាត្រា១៤ ចែងយ៉ាងច្បាស់អំពីការធានាការពារឱ្យមានជំនួយផ្នែកច្បាប់ នៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ នៅក្នុងកថាខ័ណ្ឌទី៣$_{(ឃ)}$ ក៏ដោយ ក៏រដ្ឋត្រូវបានលើកទឹកចិត្តឲ្យផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ នៅក្នុងរឿងក្តីផ្សេងទៀត ដល់បុគ្គលទាំងឡាយដែលពុំមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការបង់ថ្លៃសេវានេះ។ នៅក្នុងរឿងក្តីមួយចំនួន រដ្ឋត្រូវមានកាតព្វកិច្ចធ្វើយ៉ាងដូច្នោះតែម្តង។ ឧ. នៅពេលជនដែលត្រូវផ្តន្ទាទោសប្រហារជីវិតម្នាក់ ស្វះស្វែងរកលទ្ធភាពដាក់បណ្តឹង ឱ្យសើរើពីភាពមិនប្រក្រតីនៅក្នុងសវនាការព្រហ្មទណ្ឌ ប៉ុន្តែពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ថ្លៃជំនួយផ្នែកច្បាប់

---

[៨] បណ្តឹងលេខ២០២/១៩៩១ រវាង*Ato del Avellanal និងប្រទេសប៉េរូ* កថាខ័ណ្ឌទី១០.២ (ការកំណត់សិទ្ធិតំណាងទ្រព្យសម្បត្តិសហព័ទ្ធបានចំពោះតែប្តីនៅចំពោះមុខតុលាការ អាស្រ័យហេតុនេះ បានបដិសេធចោលសហព័ទ្ធជាស្រីមិនឲ្យប្តឹងទៅតុលាការ)។ សូមមើលផងដែរសេចក្តីពន្យល់ទូទៅលេខ១៨ (១៩៨៩) ស្តីពីការមិនរើសអើង កថាខ័ណ្ឌទី៧។

ដើម្បីធ្វើបណ្ដឹងសើរើបែបនោះបាន រដ្ឋត្រូវមានកាតព្វកិច្ច ត្រូវផ្ដល់ជំនួយផ្នែកច្បាប់ អនុលោមតាមមាត្រា១៤ កថាខ័ណ្ឌទី១ ស្របគ្នានឹងសិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធភាព តាមមាត្រា២ កថាខ័ណ្ឌទី៣ នៃកតិកាសញ្ញានេះ។[៩]

១១. ដូចគ្នានេះដែរ ការតម្រូវឱ្យភាគីនៃរឿងក្ដីបង់ប្រាក់ប្រដាប់ក្ដីអាចនឹងរារាំងតាមព្រឹត្តិហេតុដល់ពួកគេក្នុងការស្វែងរកយុត្តិធម៌និងអាចបង្កជាបញ្ហានានាតាមមាត្រា១៤ កថាខ័ណ្ឌទី១។[១០] និយាយដោយឡែក ភារកិច្ចដ៏តឹងរឹងមួយតាមផ្លូវច្បាប់ក្នុងការសងសំណងដល់ភាគីឈ្នះក្ដី ដោយគ្មានការពិចារណាអំពីកម្មវិបាករបស់វា ឬដោយគ្មានបានផ្ដល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ អាចផ្ដល់ឥទ្ធិពលអាក្រក់ដល់លទ្ធភាពរបស់បុគ្គលទាំងឡាយ ក្នុងការស្វែងរកដំណោះស្រាយអំពីសិទ្ធិនានារបស់ពួកគេ ក្រោមកតិកាសញ្ញានេះ នៅក្នុងដំណើរការនីតិវិធីដែលមានចំពោះពួកគេ។[១១]

---

[៩] បណ្ដឹងលេខ៣៧៧/១៩៨៩ រវាង*Currie និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១៣.៤*

*បណ្ដឹងលេខ៧០៤/១៩៩៦ រវាងShaw និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៦*

*បណ្ដឹងលេខ៧០៧/១៩៩៦ រវាងTaylor និងប្រតេសចាម៉ៃកា កថាខ័ណ្ឌទី៨.២*

*បណ្ដឹងលេខ៧៥២/១៩៩៧ រវាងHenry និងប្រទេសទ្រីណីដាត និង តូបាហ្គូ កថាខ័ណ្ឌទី៧.៦*

*បណ្ដឹងលេខ៨៤៥/១៩៩៨ រវាងKennedy និងប្រទេសទ្រីណីដាត និងតូបាហ្គូ កថាខ័ណ្ឌទី៧.១០*

[១០] បណ្ដឹងលេខ៦៤៦/១៩៩៥ រវាងLindon និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៦.៤។

[១១] បណ្ដឹងលេខ៧៧៩/១៩៩៧ រវាង*Äärelä and Näkkäläjärvi និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី ៧.២*

**១២.** សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការដោយស្មើភាពគ្នា ដែលមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី១ ចែងតែពីសិទ្ធិទទួលបាននីតិវិធីនៅសាលាដំបូងប៉ុណ្ណោះ ហើយមិនមានចែងពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ ឬសិទ្ធិស្វែងរកការដោះស្រាយផ្សេងទៀតនោះទេ។[១២]

**១៣.** សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី ក៏ធានាអំពីសិទ្ធិស្មើគ្នានៃភាគី ក្នុងរឿងក្តីផងដែរ។ នេះមានន័យថា សិទ្ធិទទួលបាននីតិវិធីដូចគ្នា ត្រូវផ្តល់ជូនភាគីទាំងអស់ លើកលែងតែការបែងចែក ត្រូវបានធ្វើដោយមានមូលដ្ឋានច្បាប់ និងអាចធ្វើយុត្តិកម្មបានដោយមានមូលដ្ឋានសត្យានុម័ត និងសមហេតុផល ដោយពុំដាក់គុណវិបត្តិជាក់ស្តែង ឬភាពមិនត្រឹមត្រូវផ្សេងទៀតដល់ភាគីចុងចម្លើយ។[១៣] ពុំមានសិទ្ធិស្មើគ្នានៃភាគីក្នុងរឿងក្តីនោះទេ ឧ. ប្រសិនបើមានតែព្រះរាជអាជ្ញាប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចមួយចំនួន រីឯភាគីចុងចម្លើយគ្មានសិទ្ធិបែបនេះ។[១៤] គោលការណ៍សមភាពរវាងភាគីនានា ក៏អនុវត្តផង

---

[១២] បណ្តឹងលេខ៤៥០/១៩៩១ រវាង *I.P. និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៦.២។*

[១៣] បណ្តឹងលេខ១៣៤៧/២០០៥ រវាង *Dudko និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.៤។*

[១៤] បណ្តឹងលេខ១០៨៦/២០០២ រវាង *Weiss និងប្រទេសអូទ្រីស កថាខ័ណ្ឌទី៩.៦។ ឧទាហរណ៍មួយទៀតនៃការរំលោភបំពានលើគោលការណ៍សមភាពនៃគូភាគីក្នុងរឿងក្តី សូមមើលបណ្តឹងលេខ២២៣/១៩៨៧ រវាងRobinson និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១០.៤ (ការបង្អង់សវនាការ)។*

ដែរក្នុងដំណើររឿងក្ដីរដ្ឋប្បវេណី និងទាមទារជាអាទិ៍ ភាគីនីមួយៗ ត្រូវបានផ្ដល់ឱកាសជំទាស់រាល់ការទាញហេតុផល និងភស្ដុតាង ដែលបានលើកបង្ហាញដោយភាគីម្ខាងទៀត។[១៥] ក្នុងករណីអញ្ញត្រកម្ម អ្នកបកប្រែ អាចត្រូវបានផ្ដល់ជូនដោយឥតគិតថ្លៃផងដែរ ប្រសិនបើពុំដូច្នោះទេ ភាគីក្រីក្រពុំអាចចូលរួមក្នុងដំណើរការក្ដីបានដោយស្មើភាពគ្នា ឬសាក្សីរបស់ខ្លួន ត្រូវបានសួរដេញដោលនោះទេ។

**១៤.** សិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្ដី ក៏តំរូវផងដែរថា រឿងក្ដីស្រដៀងគ្នា ត្រូវដោះស្រាយទៅតាមនីតិវិធីប្រហាក់ប្រហែលគ្នា។ ឧ. ប្រសិនបើអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌពិសេស ឬតុលាការ ឬសាលាជម្រះក្ដីដែលត្រូវបានបង្កើតឡើងជាពិសេស ដើម្បីសម្រេចសេចក្ដីលើប្រភេទរឿងក្ដីមួយចំនួន[១៦] គេត្រូវតែផ្ដល់មូលដ្ឋានជាសត្យានុម័ត និងសមហេតុផលនានា ដើម្បីធ្វើយុត្តិកម្មពីការអនុវត្តផ្សេងនេះ។

---

[១៥] បណ្ដឹងលេខ៨៤៦/១៩៩៩ រវាង*Jansen-Gielen និងប្រទេសហូឡង់ កថាខ័ណ្ឌទី៨.២ និង បណ្ដឹងលេខ៧៧៩/១៩៩៧ រវាង Äärelä និងNäkkäläjärvi និង ប្រទេសហ្វាំងឡង់ កថាខ័ណ្ឌលេខ ៧.៤។*

[១៦]ឧ. ប្រសិនបើសវនាការដោយគណៈវិនិច្ឆ័យត្រូវបានផាត់ចេញពីប្រភេទមួយចំនួននៃជនជាប់ចោទ ឬបទល្មើស (សូមអានសេចក្ដីសង្កេតសន្និដ្ឋានសំរាប់សហរាជាណាចក្រនៃចក្រភពអង់គ្លេស និង អៀកឡង់ខាងជើង *CCPR/CO/73/UK (2001) កថាខ័ណ្ឌទី១៨)*

## III. ការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីមួយមានសមត្ថកិច្ច ឯករាជ្យ និងអនាគតិ

**១៥.** សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងជាសាធារណៈ ដោយសាលាជម្រះក្តីមួយ មានសមត្ថកិច្ច ឯករាជ្យ និងអនាគតិ ដែលបង្កើតឡើងដោយច្បាប់ ត្រូវបានធានាការពារ ស្របតាមវាក្យខ័ណ្ឌទី២ នៃមាត្រា១៤ កថាខ័ណ្ឌទី១ នៅក្នុងរឿងក្តីនានាទាក់ទងនឹងការសម្រេចសេចក្តី ពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាមួយ ឬពីសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេ នៅក្នុងបណ្តឹងតាមផ្លូវច្បាប់។ ជាគោលការណ៍ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទាក់ទងនឹងអំពើនានា ដែលត្រូវប្រកាសផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាតិ។ ពាក្យនេះក៏អាចគ្របដណ្តប់ផងដែរលើអំពើនានា ដែលមានចរិតលក្ខណៈជាបទឧក្រិដ្ឋ ជាមួយនឹងការផ្តន្ទាទោសដែលត្រូវចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ដោយសារតែគោលបំណង ចរិតលក្ខណៈ ឬភាពធ្ងន់ធ្ងរនៃអំពើទាំងនោះ ដោយពុំគិតពីលក្ខណៈតម្រូវនៃអំពើទាំងនោះនៅក្នុងច្បាប់ជាតិឡើយ។[១៧]

**១៦.** ទស្សនៈនៃការកំណត់សិទ្ធិ និងកាតព្វកិច្ច *"នៅក្នុងបណ្តឹងតាមផ្លូវច្បាប់"* មានលក្ខណៈកាន់តែស្មុគស្មាញ។ យោងតាមមាត្រា៥៣ កតិកាសញ្ញានេះត្រូវបានតាក់តែងឡើងខុសៗគ្នា ទៅតាមភាសា

---

[១៧] បណ្តឹងលេខ១០១៥/២០០១ រវាង*Peterer និងប្រទេសអូទ្រីស កថាខ័ណ្ឌទី៩.២*។

ផ្សេងៗគ្នា ដែលមានតំលៃជាយថាភូតស្មើគ្នា ហើយ*ការងាររៀបចំ* ពុំទាន់បានដោះស្រាយ ពីភាពខុសគ្នានៅក្នុងអត្ថបទដែលប្រើភាសាផ្សេងៗគ្នានោះទេ។ គណៈកម្មាធិការនេះ កត់សំគាល់ថាទស្សនៈនៃ *"បណ្ដឹងតាមផ្លូវច្បាប់"* ឬសមមូលរបស់វា នៅក្នុងអត្ថបទដែលប្រើភាសាផ្សេងៗគ្នា ត្រូវផ្អែកលើចរិតលក្ខណៈនៃសិទ្ធិដែលកំពុងត្រូវពិចារណា ជាជាងផ្អែកលើឋានៈរបស់ភាគីណាមួយនៃរឿងក្ដី ឬផ្អែកលើវេទិកាដោយឡែកណាមួយ ដែលបង្កើតដោយប្រព័ន្ធគតិយុត្តក្នុងស្រុក ក្នុងការកំណត់ពីសិទ្ធិដោយឡែកនោះ។[១៨] ទស្សនៈនេះគ្របដណ្ដប់លើ៖

(ក) នីតិវិធីតុលាការដែលមានគោលដៅកំណត់ពីសិទ្ធិ និងកាតព្វកិច្ចនានាពាក់ព័ន្ធនឹងផ្នែកកិច្ចសន្យា បេតិកភ័ណ និងការទទួលខុសត្រូវរដ្ឋប្បវេណី ក្នុងវិស័យច្បាប់ឯកជន ក៏ដូចជា

(ខ) ពាក្យសមមូលនានានៅក្នុងវិស័យច្បាប់រដ្ឋបាល ដូចជាការបញ្ចប់មុខងារមន្ត្រីសាធារណៈដោយសារមូលហេតុនានាក្រៅពីមូលហេតុទណ្ឌកម្មខាងវិន័យ[១៩] ការកំណត់ពីផលប្រយោជន៍ខាងសន្តិសុខសង្គម[២០] ឬសិទ្ធិទទួលបានសោធននិវត្តន៍របស់យោធិន[២១] ឬនីតិវិធី

---

[១៨] បណ្ដឹងលេខ១១២/១៩៨១ រវាង *Y.L. និងប្រទេសកាណាដា កថាខ័ណ្ឌទី៩.១ និង៩.២។*

[១៩] បណ្ដឹងលេខ៤៤១/១៩៩០ រវាង *Casanovas និងប្រទេសបារាំង កថាខ័ណ្ឌទី៥.២។*

[២០] បណ្ដឹងលេខ៤៥៤/១៩៩១ រវាង *Garcia Pons និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៩.៣។*

[២១] បណ្ដឹងលេខ១១២/១៩៨១ រវាង *Y.L. និងប្រទេសកាណាដា កថាខ័ណ្ឌទី៩.៣។*

ទាក់ទិននឹងការប្រើប្រាស់ដីធ្លីសាធារណៈ[២២] ឬការដកហូតទ្រព្យសម្បត្តិឯកជន។ លើសពីនេះទៀត ទស្សនៈនេះអាច (គ) ទោះជាយ៉ាងណាក៏ដោយ គ្របដណ្តប់លើនីតិវិធីផ្សេងៗ ទៀតដែលត្រូវតែវាយតំលៃដោយឈរលើមូលដ្ឋានទៅតាមករណីមួយៗ តាមស្មារតីនៃចរិកលក្ខណៈនៃសិទ្ធិដែលត្រូវពិចារណា។

**១៧.** ផ្ទុយទៅវិញ សិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការ ឬសាលាជម្រះក្តីដូចមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី២ ពុំមានអនុភាពអនុវត្តនោះទេ ប្រសិនបើច្បាប់ជាតិពុំផ្តល់សិទ្ធិណាមួយ ឱ្យដល់បុគ្គលដែលពាក់ព័ន្ធ។ ហេតុដូច្នោះហើយ ទើបគណៈកម្មាធិការនេះបានតំកល់បទប្បញ្ញត្តិនេះថា មិនអាចអនុវត្តបានទេ ប្រសិនបើច្បាប់ជាតិពុំបានអនុញ្ញាតឲ្យបុគ្គលនេះមានសិទ្ធិបែបនេះ ដូចជា សិទ្ធិទទួលបានការតំលើងឋានន្តរស័ក្តនៅក្នុងមុខងារសាធារណៈ[២៣] សិទ្ធិទទួលបានការតែងតាំងជាចៅក្រម[២៤] ឬសិទ្ធិសុំបន្ធូរបន្ថយទោសប្រហារជីវិត ដោយស្ថាប័ននីតិប្រតិបត្តិ

---

[២២] បណ្តឹងលេខ៧៧៩/១៩៩៧ រវាង*Äärelä និង Näkkäläjärvi និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី ៧.២ ដល់ ៧.៤។*

[២៣] បណ្តឹងលេខ៨៣៧/១៩៩៨ រវាង*Kolanowski និងប្រទេសប៉ូឡូញ កថាខ័ណ្ឌទី៦.៤។*

[២៤] បណ្តឹងលេខ៩៧២/២០០១ រវាង*Kazantzis និងប្រទេសសាយប្រឺស កថាខ័ណ្ឌទី៦.៥ បណ្តឹងលេខ៩៤៣/២០០០ រវាង Jacobs និងប្រទេសបែលហ្ស៊ិក កថាខ័ណ្ឌទី៨.៧ និងបណ្តឹងលេខ១៣៩៦/២០០៥ រវាងRivera Fernández និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៦.៣។*

ជាដើម។[២៥] លើសពីនេះទៅទៀត គ្មានការកំណត់សិទ្ធិ និងកាតព្វកិច្ចនៅក្នុងបណ្តឹងតាមផ្លូវច្បាប់នោះទេ ប្រសិនបើបុគ្គលនេះត្រូវប្រឈមមុខនឹងវិធានការនានា ដែលត្រូវបានចាត់ឡើង ដោយមន្ត្រីដែលមានឋានានុក្រមរដ្ឋបាលខ្ពស់ជាងគាត់ ដូចជា វិធានការវិន័យ ដែលមិនក្លាយជាការដាក់ទោសផ្នែកព្រហ្មទណ្ឌ ប្រឆាំងនឹងមន្ត្រីសាធារណៈ[២៦] សមាជិកកងកំលាំងប្រដាប់អាវុធ ឬអ្នកទោសជាដើម។ បន្ថែមពីនេះ ការធានាការពារនេះមិនអនុវត្តចំពោះនីតិវិធីនៃការធ្វើបត្យាប័ន ការបណ្តេញចេញ និងនិរទេសនោះទេ។[២៧] ទោះបីជាគ្មានសិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីតុលាការ ឬសាលាជម្រះក្តី ដូចមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី២ ក៏ដោយ ក៏ក្នុងរឿងក្តីទាំងអស់ខាងលើ និងរឿងក្តីប្រហាក់ប្រហែល នៅតែមានការធានាការពារតាមនីតិវិធីផ្សេងទៀត ដែលអាចយកមកអនុវត្តបានដែរ។[២៨]

---

[២៥] បណ្តឹងលេខ៨៤៥/១៩៩៨ *រវាងKennedy និងប្រទេសទ្រីណីដាត និងតូបាហ្គូ កថាខ័ណ្ឌទី៧.៤។*

[២៦] បណ្តឹងលេខ១០១៥/២០០១ *រវាងPerterer និងប្រទេសអូទ្រីស កថាខ័ណ្ឌទី៩.២ (បណ្តេញចេញដោយទណ្ឌកម្មវិន័យ)។*

[២៧] បណ្តឹងលេខ១៣៤១/២០០៥ *រវាងZundel និងប្រទេសកាណាដា កថាខ័ណ្ឌទី៦.៨ និងបណ្តឹងលេខ១៣៥៩/២០០៥ រវាងEsposito និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៧.៦។*

[២៨] សូមមើលកថាខ័ណ្ឌទី៦២ ខាងក្រោម នៃសេចក្តីពន្យល់នេះ។

១៨. ពាក្យ "សាលាជម្រះក្តី" នៅក្នុងមាត្រា១៤ កថាខ័ណ្ឌទី១ ដោយមិនគិតពីការហៅឈ្មោះស្ថាប័ននេះ គឺជាស្ថាប័នមួយដែលបង្កើតឡើងដោយច្បាប់ ឯករាជ្យពីអង្គនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ ឬមានឯករាជភាពខាងយុត្តាធិការលើរឿងក្តីជាក់លាក់នានាក្នុងការសម្រេចសេចក្តីលើបញ្ហាច្បាប់ នៅក្នុងដំណើរការនៃរឿងក្តីដែលមានចរិកលក្ខណៈជាការវិនិច្ឆ័យ។ មាត្រា១៤ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី២ ធានាការពារសិទ្ធិទទួលបានសេវាកម្មយុត្តិធម៌ពីសាលាជម្រះក្តីបែបនេះ ចំពោះជនគ្រប់រូបដែលប្រឈមនឹងការចោទប្រកាន់ពីបទអាជ្ញា។ សិទ្ធិនេះមិនអាចត្រូវបានរឹតត្បិតនោះទេ ហើយការផ្តន្ទាទោសព្រហ្មទណ្ឌណាមួយ ដោយស្ថាប័នដែលមិនបង្កើតជាសាលាជម្រះក្តី គឺមិនស្របនឹងបទប្បញ្ញត្តិនេះទេ។ ដូចគ្នានេះដែរ នៅពេលណាដែលសិទ្ធិ និងកាតព្វកិច្ច នៅក្នុងបណ្តឹងតាមផ្លូវច្បាប់ ត្រូវបានកំណត់ការសម្រេចនេះ ត្រូវតែធ្វើយ៉ាងហោចណាស់ក៏នៅត្រឹមដំណាក់កាលណាមួយនៃដំណើរការរឿងក្តីដោយសាលាជម្រះក្តីទៅតាមខ្លឹមសារនៃវាក្យខ័ណ្ឌនេះដែរ។ ការខកខានរបស់រដ្ឋភាគី ក្នុងការបង្កើតសាលាជម្រះក្តីមួយ ដែលមានសមត្ថភាព ដើម្បីកំណត់ពីសិទ្ធិ និងកាតព្វកិច្ចនានា ឬដើម្បីផ្តល់សិទ្ធិឲ្យទទួលបានសេវាកម្មយុត្តិធម៌ពីសាលាជម្រះក្តីបែបនេះ នៅក្នុងរឿងក្តីជាក់លាក់នានា នឹងត្រូវចាត់ទុកថាជាការរំលោភបំពានលើមាត្រា ១៤ ក្នុងស្ថានភាពនានាដូចតទៅ៖

- ប្រសិនបើការរឹតត្បិតទាំងនេះ មិនពឹងផ្អែកលើច្បាប់ក្នុងស្រុក

- ប្រសិនបើការរឹតត្បិតទាំងនេះ មិនចាំបាច់ធ្វើតាមគោលបំណងច្បាប់ ដូចជារដ្ឋបាលយុត្តិធម៌ត្រឹមត្រូវ ឬ
- ប្រសិនបើការរឹតត្បិតទាំងនេះ មិនពឹងផ្អែកលើអញ្ញត្រកម្មពីយុត្តាធិការដែលកើតចេញពីច្បាប់អន្តរជាតិ ឧ. ដូចជាអភ័យឯកសិទ្ធិ ឬ
- ប្រសិនបើសិទ្ធិទទួលបាននេះ ទុកសំរាប់តែបុគ្គលណាម្នាក់អាចនឹងត្រូវរឹតត្បិតក្នុងវិសាលភាពមួយ ដែលនឹងធ្វើឱ្យអន្តរាយដល់ខ្លឹមសារជាសារវន្តនៃសិទ្ធិនេះ។

**១៩.** លក្ខខណ្ឌតំរូវនៃសមត្ថកិច្ច ឯករាជភាព និងអនាគតិរបស់សាលាជម្រះក្តី នៅក្នុងខ្លឹមសារនៃមាត្រា១៤ កថាខ័ណ្ឌទី១ គឺជាសិទ្ធិដាច់ខាត ដែលមិនអនុញ្ញាតឲ្យធ្វើអញ្ញត្រកម្មនោះទេ។[២៩] លក្ខខណ្ឌតំរូវនៃឯករាជភាព សំដៅជាពិសេស ទៅលើនីតិវិធី និងលក្ខណៈសម្បត្តិសម្រាប់ការតែងតាំងចៅក្រម និងសំដៅទៅលើការធានា ការពារទាក់ទិននឹងសុវត្ថិភាពកាន់មុខតំណែងរបស់ពួកគេរហូតដល់អាយុចូលនិវត្តន៍តាមច្បាប់កំណត់ ឬចប់អាណត្តិកាន់តំណែងរបស់ពួកគេ ប្រសិនបើករណីបែបនេះមាន និងសំដៅទៅលើលក្ខខណ្ឌស្តីពីការតំលើងឋានន្តរសក្តិ៍ ការផ្លាស់ប្តូរ ការព្យួរមុខងារ និងការបញ្ឈប់ពីមុខងាររបស់ពួកគេ ព្រមទាំងសំដៅដល់ឯករាជភាពពិតប្រាកដរបស់តុលាការ ពីការជ្រៀតជ្រែកខាង

---
[២៩] បណ្តឹងលេខ២៦៣/១៩៨៧ រវាង *Gonzalez del Rio និងប្រទេសប៉េរូ កថាខ័ណ្ឌទី៥.២។*

នយោបាយ ដោយអំណាចនីតិប្រតិបត្តិ និងអំណាចនីតិបញ្ញត្តិ។ រដ្ឋគួរតែចាត់វិធានការជាក់លាក់នានា ក្នុងការធានា ការពារដល់ឯករាជភាពរបស់តុលាការ ការពារចៅក្រមពីឥទ្ធិពលនយោបាយតាមទម្រង់ណាមួយ នៅក្នុងការធ្វើសម្រេចសេចក្តីរបស់ខ្លួន តាមរយៈរដ្ឋធម្មនុញ្ញ ឬការអនុម័តច្បាប់នានាដែលចែងច្បាស់លាស់ពីនីតិវិធី និងលក្ខណៈវិនិច្ឆ័យឥតលំអៀង សម្រាប់ការតែងតាំងលាភការ អាណត្តិមុខងារ ការដំលើងឋានន្តរសក្តិ ការព្យួរមុខងារ និងការបណ្តេញចេញពីមុខតំណែង និងការដាក់ទណ្ឌកម្មខាងវិន័យលើពួកគេ។[៣០] ប្រសិនបើស្ថិតក្នុងស្ថានភាពមួយដែលមុខងារ និងសមត្ថកិច្ចរបស់តុលាការ និងអង្គនីតិប្រតិបត្តិ មិនត្រូវបានញែកដាច់ពីគ្នាច្បាស់លាស់ទេ ឬប្រសិនបើអង្គនីតិប្រតិបត្តិ អាចគ្រប់គ្រង ឬដឹកនាំតុលាការបាន នោះមានន័យថា មិនស្របតាមពាក្យ "សាលាជម្រះក្តីមួយ" ឯករាជ្យឡើយ។[៣១] កិច្ចការពារចៅក្រម ពីទំនាស់ផលប្រយោជន៍និងការគំរាមកំហែងគឺជាការចាំបាច់ណាស់។ ដើម្បីការពារឯករាជភាពរបស់តុលាការ ឋានៈជាចៅក្រម រួមមានអណត្តិកាន់មុខដំណែង ឯករាជភាព សុវត្ថិភាព លាភការសមរម្យ លក្ខខណ្ឌការងារ ប្រាក់សោធននិវត្តន៍ និងអាយុនៃការចូលនិវត្តន៍របស់ចៅក្រម ត្រូវតែធានាឱ្យបានគ្រប់គ្រាន់ដោយច្បាប់។

---

[៣០] សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសស្លូវ៉ាគី CCPR/C/79/Add.79 (1997), *កថាខ័ណ្ឌទី១៨*។

[៣១] បណ្តឹងលេខ៤៦៨/១៩៩១ រវាងOló Bahamonde និងប្រទេសអេក្វាទ័រ ហ្គីណេ *កថាខ័ណ្ឌទី ៩.៤*។

២០. ចៅក្រម អាចត្រូវបានបញ្ឈប់ពីមុខតំណែង តែក្នុងករណីប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ឬអសមត្ថភាព យោងតាមនីតិវិធីត្រឹមត្រូវ ធានាដល់ភាពជាសត្យានុម័ត និងអនាគតិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់។ ការបញ្ឈប់ចៅក្រមដោយអង្គនីតិប្រតិបត្តិ ឧ. មុនពេលចប់អាណត្តិដែលពួកគេត្រូវបានតែងតាំងដោយគ្មានហេតុផលជាក់លាក់ណាមួយ និងដោយគ្មានការការពារតាមផ្លូវតុលាការប្រកបដោយប្រសិទ្ធភាព ដើម្បីប្តឹងតវ៉ាចំពោះការបញ្ឈប់នោះទេ មានន័យថា មិនស្របនឹងឯករាជភាពរបស់តុលាការឡើយ។[៣២] ករណីស្រដៀងគ្នានេះ ក៏មិនស្របនឹងឯករាជភាពរបស់តុលាការដែរ តួយ៉ាង អង្គនីតិប្រតិបត្តិ បញ្ឈប់ចៅក្រមដែលត្រូវបានចោទប្រកាន់ដោយគ្មានភស្តុតាងពីបទពុករលួយ ដោយពុំគោរពតាមនីតិវិធីណាមួយ ដែលកំណត់ដោយច្បាប់ឡើយ។[៣៣]

២១. លក្ខខណ្ឌតំរូវនៃអនាគតិមានទិដ្ឋភាពពីរ។

⇒ ទីមួយៈ ចៅក្រមមិនត្រូវអនុញ្ញាតឲ្យការសំរេចសេចក្តីរបស់ខ្លួន

- ទទួលរងឥទ្ធិពលដោយភាពលំអៀង ឬ
- ការរើសអើងផ្ទាល់ខ្លួន ឬ
- ក៏មិនត្រូវធ្វើបុរេវិនិច្ឆ័យលើរឿងក្តីជាក់លាក់ណាមួយ ដែលខ្លួនកំពុងចាត់ការនោះទេ ឬ

[៣២] បណ្តឹងលេខ៨១៤/១៩៩៨ រវាង *Pastukhov និងប្រទេសបេលឡារុស កថាខ័ណ្ឌទី៧.៣។*

[៣៣] បណ្តឹងលេខ៩៣៣/២០០០ រវាង *Mundyo Busyo et al និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខ័ណ្ឌទី៥.២។*

- ក៏មិនត្រូវប្រព្រឹត្តតាមវិធីដែលលើកកំពស់មិនត្រឹមត្រូវ នូវផលប្រយោជន៍នៃភាគីមួយ ដោយធ្វើឱ្យខូចប្រយោជន៍ភាគីមួយផ្សេងទៀត។[៣៤]

⇒ ទីពីរៈ សាលាជម្រះក្តីក៏ត្រូវតែបង្ហាញថាខ្លួនជាអ្នកពិនិត្យរឿងក្តីមួយដ៏សមហេតុផល ធ្វើឱ្យឃើញពីភាពមិនលំអៀងរបស់ខ្លួនដែរ។ ឧ.សវនាការមួយដែលទទួលរងឥទ្ធិពលជាសារវន្តដោយការចូលរួមពីចៅក្រមដែលត្រូវបានប្តឹងជិតចិត្ត ក្រោមលក្ខន្តិកៈចៅក្រម ជាធម្មតា មិនអាចត្រូវចាត់ទុកថាមានអនាគតិទៀតនោះទេ។[៣៥]

**២២.** បទប្បញ្ញត្តិនៃមាត្រា១៤ អនុវត្តចំពោះតុលាការ និងសាលាជម្រះក្តីទាំងអស់នៅក្នុងវិសាលភាពនៃមាត្រានេះ ទោះជាតុលាការធម្មតា ឬតុលាការឯកទេស តុលាការស៊ីវិល ឬយោធា។ គណៈកម្មាធិការនេះកត់សំគាល់ពីអត្ថិភាពនៃតុលាការយោធា ឬតុលាការពិសេសដែលជំនុំជម្រះជនស៊ីវិល មាននៅក្នុងប្រទេសជាច្រើន។ ទោះជាកតិកាសញ្ញានេះ មិនហាមឃាត់ឲ្យជំនុំជម្រះជនស៊ីវិល នៅក្នុងតុលាការយោធា ឬតុលាការពិសេស ក៏កតិកាសញ្ញានេះតំរូវថាសវនាការបែបនេះ ត្រូវអនុលោមទាំងស្រុង តាមលក្ខខណ្ឌតំរូវនៃ

---

[៣៤] បណ្តឹងលេខ៣៨៧/១៩៨៩ រវាង*Karttunen និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៧.២។*

[៣៥] ដូចគ្នាពីខាងលើ។

មាត្រា១៤ ហើយថា ការធានាការពារតាមមាត្រានេះ មិនអាចត្រូវបានរឹតត្បិត ឬកែសម្រួល ដោយសារតែចរិតលក្ខណៈជាយោធា ឬពិសេសនៃតុលាការសាមីនោះឡើយ។ គណៈកម្មាធិការនេះក៏គត់សំគាល់ផងដែរថា ការជំនុំជម្រះជនស៊ីវិលនៅក្នុងតុលាការយោធា ឬតុលាការពិសេសអាចកើតឡើងនូវបញ្ហាធ្ងន់ធ្ងរជាច្រើន ដរាបណាមានការពាក់ព័ន្ធដល់រដ្ឋបាលយុត្តិធម៌ប្រកបដោយសមធម៌អនាគតិ និងឯករាជ្យ។ ហេតុដូច្នោះហើយ វាសំខាន់ណាស់ដែលត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាថា ការជំនុំជម្រះបែបនេះ ប្រព្រឹត្តទៅក្រោមលក្ខខណ្ឌ ដែលគោរពបានទាំងស្រុង តាមការធានាការពារដូចមានចែងក្នុងមាត្រា១៤។ ការជំនុំជម្រះជនស៊ីវិលដោយតុលាការយោធា ឬតុលាការពិសេស គួរតែជាករណីអញ្ញត្រកម្ម[៣៦]

ខ. មានសមត្ថកិច្ចតែលើរឿងក្តីណា ដែលរដ្ឋភាគីអាចបង្ហាញថា ជម្រើសប្រើប្រាស់ការជំនុំជម្រះបែបនេះ គឺជាការចាំបាច់ និងត្រូវធ្វើយុត្តិកម្មដោយហេតុផលជាសត្យានុម័ត និងសមហេតុផលបំផុត ហើយត្រូវអនុវត្តតែក្នុងករណីនៃប្រភេទបុគ្គល និងបទល្មើសជាក់លាក់នានា ដែលតុលាការស៊ីវិលធម្មតា មិនអាចយកទៅជំនុំជម្រះបាន។[៣៧]

[៣៦] សូមមើលអនុសញ្ញាទាក់ទិននឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩ មាត្រា៦៤ និងសេចក្តីពន្យល់ទូទៅលេខ៣១ (២០០៤) ស្តីពី *ចរិតលក្ខណៈនៃកាតព្វកិច្ចគតិយុត្តទូទៅដែលបានដាក់លើរដ្ឋភាគីនៃអនុសញ្ញានេះ កថាខ័ណ្ឌទី១១។*

[៣៧] សូមមើលបណ្តឹងលេខ១១៧២/២០០៣ រវាង*Madani និងប្រទេសអាល់ហ្សេរី កថាខ័ណ្ឌទី៨.៧*

**២៣.** ប្រទេសមួយចំនួន បានជ្រើសយកសាលាជម្រះក្តីពិសេសនៃ "ចៅក្រមលាក់មុខ" ដែលមានសមាសភាពចៅក្រមអនាមិក ឧ. នៅក្នុងវិធានការប្រយុទ្ធប្រឆាំងនឹងសកម្មភាពភេរវកម្មជាដើម។ ទោះបីជាអត្តសញ្ញាណ និងឋានៈរបស់ចៅក្រមទាំងនេះត្រូវបានបញ្ជាក់ដោយអាជ្ញាធរឯករាជ្យមួយក៏ដោយ ក៏តុលាការបែបនេះជានិច្ចកាលមិនគ្រាន់តែរងផលប៉ះពាល់ពីតថភាពដែលឋានៈ និងអត្តសញ្ញាណរបស់ចៅក្រម មិនត្រូវបានបង្ហាញឲ្យជនជាប់ចោទដឹងប៉ុណ្ណោះទេ ប៉ុន្តែក៏រងផលប៉ះពាល់ពីភាពមិនប្រក្រតីនានា ដូចជាការផាត់ចេញសាធារណជន ឬសូម្បីតែជនជាប់ចោទ និងអ្នកតំណាងរបស់ពួកគេ[៣៨] ពីដំណើរការនីតិវិធី[៣៩] ការរឹតត្បិតសិទ្ធិទទួលបានមេធាវីតាមការជ្រើសរើសផ្ទាល់ខ្លួន[៤០] ការរឹតត្បិតដ៏តឹងរឹង ឬការបដិសេធសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយមេធាវីរបស់ពួកគេ ជាពិសេសនៅពេលជាប់ឃុំដោយនៅដាច់តែឯង[៤១] ការគំរាមកំហែងមេធាវី[៤២] ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការពាររឿងក្តី[៤៣] ឬការរឹតត្បិតដ៏តឹងរឹង ឬការបដិសេធសិទ្ធិក្នុងការកោះហៅ និងត្រួតពិនិត្យ

[៣៨] បណ្តឹងលេខ១២៩៨/២០០៤ រវាង*Becerra Barney និងប្រទេសកូឡុំប៊ី កថាខ័ណ្ឌទី៧.២។*

[៣៩] បណ្តឹងលេខ៥៧៧/១៩៩៤ រវាង*Polay Campos និងប្រទេសប៉េរូ កថាខ័ណ្ឌទី៨.៨* បណ្តឹង*លេខ៦៧៨/១៩៩៦ រវាងGutierrez Vivanco និងប្រទេសប៉េរូ កថា ខ័ណ្ឌទី៧.១* និងបណ្តឹងលេខ*១១២៦/២០០២ រវាងCarranza Alegre និងប្រទេសប៉េរូ កថាខ័ណ្ឌទី៧.៥។*

[៤០] បណ្តឹងលេខ៦៧៨/១៩៩៦ រវាងGutierrez Vivanco និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.១*។

[៤១] បណ្តឹងលេខ៥៧៧/១៩៩៤ រវាងPolay Campus និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៨.៨* *បណ្តឹងលេខ១១២៦/២០០២* រវាងCarranza Alegre និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.៥*។

[៤២] បណ្តឹងលេខ១០៥៨/២០០២ រវាងVargas Mas និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៦.៤*។

[៤៣] បណ្តឹងលេខ១១២៥/២០០២ រវាង*Guispe Roque* និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.៣។*

សាក្សី រួមទាំងការហាមឃាត់មិនឲ្យសួរដេញដោលប្រភេទសាក្សីមួយចំនួន ឌ. មន្ត្រីនគរបាលដែលទទួលខុសត្រូវក្នុងការឃាត់ខ្លួន និងសួរចម្លើយជនជាប់ចោទ។[៤៤] សាលាជម្រះក្តី មាន ឬពុំមាន "ចៅក្រមលាក់មុខ" នៅក្នុងកាលៈទេសៈបែបខាងលើនេះពុំបំពេញបានតាមស្តង់ដារមូលដ្ឋាន នៃការជំនុំជម្រះដោយយុត្តិធម៌នោះទេ និងជាពិសេសពុំបំពេញបានតាមលក្ខខណ្ឌតំរូវដែលចែងថាសាលាជម្រះក្តីត្រូវតែឯករាជ្យ និងអនាគតិនោះទេ។[៤៥]

២៤. មាត្រា១៤ ក៏ពាក់ព័ន្ធផងដែរ នៅពេលដែលរដ្ឋទទួលស្គាល់តុលាការដែលផ្អែកលើច្បាប់ប្រពៃណី ឬតុលាការសាសនា នៅក្នុងសណ្តាប់ធ្នាប់គតិយុត្តរបស់ខ្លួន ក្នុងការអនុវត្ត ឬផ្តល់សិទ្ធិឲ្យតុលាការបែបនេះ នូវភារកិច្ចយុត្តាធិការ។ រដ្ឋនោះត្រូវធានាថាតុលាការបែបនេះ ពុំអាចចេញសាលក្រម ដែលមានអានុភាពយកទៅអនុវត្តបានទេ ប្រសិនបើលក្ខខណ្ឌតំរូវនានាដូចខាងក្រោម មិនត្រូវបានគោរពតាមទេនោះ៖

- នីតិវិធីនៅចំពោះមុខតុលាការបែបនេះ មានកំរិតត្រឹមតែជារឿងក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌតូចតាច

---

[៤៤] បណ្តឹងលេខ៦៧៨/១៩៩៦ រវាងGutierrez Vivanco និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.១* បណ្តឹងលេខ១១២៦/២០០២ រវាងCarranza Alegre និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.៥* បណ្តឹងលេខ១១២៥/២០០២ រវាងQuispe Roque និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.៣* និង បណ្តឹងលេខ១០៥៨/២០០២ រវាងVargas Mas និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៦.៤*។

[៤៥] បណ្តឹងលេខ៥៧៧/១៩៩៤ រវាង*Polay Campos* និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៨.៨* *បណ្តឹងលេខ៦៧៨/១៩៩៦ រវាងGutierrez Vivanco* និងប្រទេសប៉េរូ *កថាខ័ណ្ឌទី៧.១*។

- បំពេញតាមលក្ខខណ្ឌតំរូវជាមូលដ្ឋាន នៃការជំនុំជម្រះដោយយុត្តិធម៌ និងការធានាការពារដែលពាក់ព័ន្ធដទៃទៀតនៃកតិកាសញ្ញានេះ និង
- សាលក្រមនៃតុលាការទាំងនេះ ត្រូវផ្ដល់សុពលភាពដោយតុលាការជាតិ ក្នុងស្មារតីនៃការធានាការពារ ដូចមានចែងក្នុងកតិកាសញ្ញានេះ ហើយសាលក្រមនេះ អាចត្រូវបានប្ដឹងឧបាស្រ័យដោយភាគីនានាដែលពាក់ព័ន្ធក្នុងនីតិវិធី អនុលោមតាមលក្ខខណ្ឌតំរូវនៃមាត្រា១៤ នៃកតិកាសញ្ញានេះ។

ទោះជាដូច្នោះក៏ដោយ គោលការណ៍ទាំងនេះគឺជាកាតព្វកិច្ចទូទៅរបស់រដ្ឋ ក្នុងការការពារសិទ្ធិនានាក្រោមកតិកាសញ្ញានេះ របស់បុគ្គលណាមួយដែលរងប៉ះពាល់ ដោយប្រតិបត្តិការរបស់តុលាការប្រពៃណី ឬតុលាការសាសនានោះ។

**២៥.** ពាក្យ "ការជំនុំជម្រះដោយយុត្តិធម៌" រួមមានការធានាការពារសវនាការដោយយុត្តិធម៌ និងជាសាធារណៈ។ ភាពត្រឹមត្រូវនៃនីតិវិធី រួមមាន៖

- អវត្តមាននៃឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់ណាមួយ
- ការដាក់សម្ពាធ ឬការបំភិតបំភ័យ ឬ
- ការរំលោភបំពានពីសំណាក់ភាគីណាមួយ និង
- ដើម្បីបុព្វហេតុអ្វីមួយក៏ដោយ។

សវនាការមួយពុំមានភាពយុត្តិធម៌ទេ ឧ. ប្រសិនបើភាគីចុងចម្លើយក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវប្រឈមនឹងការសំដែងឥរិយាបទអរិភាពពីសាធារណជន ឬក៏ការគាំទ្រតែភាគីម្ខាង នៅក្នុងបន្ទប់សវនាការដែលទទួលបានការអធ្យាស្រ័យពីតុលាការ ជាហេតុនាំឲ្យមានការរំលោភបំពានលើសិទ្ធិក្នុងការការពារ[៤៦] ឬត្រូវដាក់ឲ្យប្រឈមនឹងការសំដែងឥរិយាបទអរិភាពផ្សេងៗទៀត ដែលមានផលប៉ះពាល់ប្រហាក់ប្រហែលគ្នា។ ការសំដែងឥរិយាបទរើសអើងពូជសាសន៍ដោយគណៈវិនិច្ឆ័យ[៤៧] ដែលត្រូវបានអធ្យាស្រ័យដោយសាលាជម្រះក្តី ឬការជ្រើសរើសគណៈវិនិច្ឆ័យដែលមានលក្ខណៈលំអៀងខាងពូជសាសន៍ គឺជាឧទាហរណ៍មួយទៀត ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ភាពត្រឹមត្រូវនៃនីតិវិធី។

**២៦**. មាត្រា១៤ គ្រាន់តែធានាការពារសមភាព និងភាពត្រឹមត្រូវខាងនីតិវិធីតែប៉ុណ្ណោះ និងពុំអាចត្រូវបានបកស្រាយថាជាការធានាពីភាពគ្មានកំហុស របស់សាលាជម្រះក្តីមានសមត្ថកិច្ចឡើយ។[៤៨] ជាទូទៅ វាគឺជាសមត្ថកិច្ចរបស់តុលាការនៃរដ្ឋភាគីរបស់កតិកាសញ្ញានេះ ក្នុងការពិនិត្យលើអង្គហេតុ និងភស្តុតាងនានា ឬការអនុវត្តច្បាប់ជាតិ នៅក្នុងរឿងក្តីជាក់លាក់ណាមួយ លុះត្រាតែគេ

[៤៦] បណ្តឹងលេខ៧៧០/១៩៩៧ រវាង*Gridin និងសហព័ន្ធរុស្ស៊ី កថាខណ្ឌទី៨.២*។

[៤៧] សូមមើលគណៈកម្មាធិការស្តីពីការបំបាត់ការរើសអើងពូជសាសន៍ បណ្តឹងលេខ៣/១៩៩១ រវាង *Narrainen និងប្រទេសណរវេស កថាខណ្ឌទី៩.៣*។

[៤៨] បណ្តឹងលេខ២៧៣/១៩៨៨ រវាងB.d.B និងប្រទេសហូឡង់ *កថាខណ្ឌទី៦.៣*។ បណ្តឹងលេខ១០៩៧/២០០២ រវាងMartinez Mercader et al និងប្រទេសអេស្ប៉ាញ *កថាខណ្ឌទី៦.៣*។

អាចបង្ហាញឲ្យឃើញថា ការវាយតំលៃ ឬការអនុវត្តបែបនេះ ជាការប្រព្រឹត្តតាមទំនើងចិត្តយ៉ាងច្បាស់ក្រឡែត ឬឈានដល់ការបង្ហាញកំហុសយ៉ាងជាក់លាក់ ឬ*យុត្តិនិសេធ* ឬម្យ៉ាងវិញទៀត តុលាការត្រូវបានរកឃើញថា បានរំលោភលើកាតព្វកិច្ចប្រកាន់ឯករាជភាព និងភាពមិនលំអៀងរបស់ខ្លួន។[៤៩] ចៅក្រមត្រូវផ្តល់ការណែនាំជាក់លាក់ដល់គណៈវិនិច្ឆ័យក្រោមស្តង់ដារដូចគ្នានេះ នៅក្នុងសវនាការដែលមានគណៈវិនិច្ឆ័យ។[៥០]

**២៧.** ទិដ្ឋភាពសំខាន់មួយនៃភាពត្រឹមត្រូវនៃសវនាការ គឺភាពឆាប់រហ័សរបស់វា។ ទន្ទឹមនឹងបញ្ហានៃការពន្យាពេលមិនត្រឹមត្រូវ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវបានលើកឡើងយ៉ាងច្បាស់លាស់ នៅក្នុងកថាខ័ណ្ឌទី៣(គ) នៃមាត្រា១៤ ការពន្យាពេលនៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី ដែលពុំអាចធ្វើយុត្តិកម្មបានដោយសារភាពស្មុគស្មាញនៃរឿងក្តី ឬឥរិយាបទរបស់ភាគីនានាគឺជាទង្វើងាកចេញពីគោលការណ៍នៃការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងក្នុងកថាខ័ណ្ឌទី១ នៃបទប្បញ្ញត្តិនេះ។[៥១] ប្រសិនបើការពន្យា

[៤៩] បណ្តឹងលេខ១១៨៨/២០០៣ រវាង*Riedl-Riedestein et al.* និងប្រទេសអាឡឺម៉ង់ កថាខ័ណ្ឌទី៧.៣។ *បណ្តឹងលេខ៨៨៦/១៩៩៩ រវាងBondarenko និងប្រទេសប៊ែលឡារូស កថាខ័ណ្ឌទី៩.៣ បណ្តឹងលេខ១១៣៨/២០០២រវាងArenz et al.និងប្រទេសអាឡឺម៉ង់ស្តីពីការសម្រេចសេចក្តីប្រវេស នីយ៍ កថាខ័ណ្ឌទី៨.៦។*

[៥០] បណ្តឹងលេខ២៥៣/១៩៨៧ រវាង*Kelly និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៥.១៣*
*បណ្តឹងលេខ៣៤៩/១៩៨៩ រវាងWright និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៨.៣*

[៥១] បណ្តឹងលេខ២០៣/១៩៨៦ រវាង*Munoz Hermoza និងប្រទេសប៉េរូ កថាខ័ណ្ឌទី១១.៣*
*បណ្តឹងលេខ៥១៤/១៩៩២ រវាងFei និងប្រទេសកូឡុំប៊ី កថាខ័ណ្ឌទី៨.៤។*

ពេលបែបនេះ ត្រូវបានបង្កឡើងដោយកង្វះធនធាន និងការផ្តល់មូលនិធិ មិនគ្រប់គ្រាន់ជាប្រចាំ គេគួរតែលៃទុកធនធានហិរញ្ញវត្ថុបំពេញបន្ថែមឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន សម្រាប់រដ្ឋបាលយុត្តិធម៌។[៥២]

**២៨.** គ្រប់ការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ឬទាក់ទិននឹងបណ្តឹងតាមផ្លូវច្បាប់ ជាគោលការណ៍ ត្រូវតែប្រព្រឹត្តទៅដោយផ្ទាល់មាត់ និងជាសាធារណៈ។ សវនាការជាសាធារណៈ ធានាដល់តម្លាភាពនៃដំណើរការនីតិវិធី ហេតុដូច្នោះ ភាពជាសាធារណៈនេះ ផ្តល់ការការពារជាសារវន្តដល់ផលប្រយោជន៍របស់ឯកត្តបុគ្គល និងសង្គមជាទូទៅ។ តុលាការ ត្រូវតែជូនដំណឹងអំពីពេលវេលា និងទីកន្លែងនៃសវនាការផ្ទាល់មាត់ ដល់សាធារណជន ព្រមទាំងផ្តល់មធ្យោបាយគ្រប់គ្រាន់ សម្រាប់ការចូលរួមរបស់សាធារណជន ដែលចាប់អារម្មណ៍ នៅក្នុងកំរិតដ៏សមហេតុផល ជាអាទិ៍ ដោយគិតទៅដល់ផលប្រយោជន៍ជាសក្តានុពលក្នុងរឿងក្តីនិងរយៈពេលនៃសវនាការផ្ទាល់មាត់។[៥៣] លក្ខខណ្ឌតម្រូវឱ្យមានសវនាការសាធារណៈ មិនចាំបាច់អនុវត្ត លើគ្រប់នីតិវិធីឧទ្ធរណ៍ ដែលសវនាការអាចប្រព្រឹត្តទៅតែនៅលើកំណត់ហេតុយកចំលើយឬសំណៅជាលាយលក្ខណ៍

[៥២] សូមមើលឧទាហរណ៍. សេចក្តីសង្កេតសន្និដ្ឋាន សំរាប់សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ CCPR/C/COD/CO/3 (2006), *កថាខ័ណ្ឌទី២១* សេចក្តីសង្កេតសន្និដ្ឋានសំរាប់សាធារណៈរដ្ឋអាហ្វ្រិចកណ្តាល CCPR/C/CAF/CO/2 (2006), *កថាខ័ណ្ឌទី១៦*។

[៥៣] បណ្តឹងលេខ២១៥/១៩៨៦ រវាងVan Meurs និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.២

អក្សរនោះទេ[៥៤] ឬក៏ការធ្វើសេចក្ដីសម្រេច មុនអង្គសេចក្ដីដោយព្រះរាជអាជ្ញា និងអាជ្ញាធរសាធារណៈដទៃទៀត។[៥៥]

**២៩.** មាត្រា១៤ កថាខ័ណ្ឌទី១ ទទួលស្គាល់ថា តុលាការមានអំណាចក្នុងការផាត់សាធារណជនចេញទាំងអស់ ឬផ្នែកណាមួយដោយហេតុផលសីលធម៌ សណ្ដាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ ឬនៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់ភាគីនានា តំរូវឱ្យធ្វើយ៉ាងដូច្នោះ ឬដល់កំរិតមួយដែលចាំបាច់បំផុត នៅក្នុងកាលៈទេសៈពិសេសដែលតុលាការយល់ឃើញថា សវនាការជាសាធារណៈអាចនឹងធ្វើឲ្យខូចប្រយោជន៍ដល់យុត្តិធម៌។ ក្រៅពីកាលៈទេសៈពិសេសបែបនេះ សវនាការត្រូវតែបើកចំហដល់សាធារណជនទូទៅ រួមទាំង សមាជិកនៃប្រព័ន្ធផ្សព្វផ្សាយ និងជាឧទាហរណ៍ មិនត្រូវកំរិតត្រឹមតែបុគ្គលប្រភេទជាក់លាក់ណាមួយនោះទេ។ ទោះបីជាក្នុងករណីដែលសាធារណជនត្រូវបានផាត់ចេញពីសវនាការក៏ដោយ ក៏សាលក្រម រួមទាំងការរកឃើញភស្ដុតាង និងការទាញហេតុផលគតិយុត្តសំខាន់ៗត្រូវតែធ្វើជាសាធារណៈ លើកលែងតែផលប្រយោជន៍របស់អនីតិជនតំរូវផ្សេងពីនេះ ឬដំណើរការនីតិវិធីទាក់ទិននឹងវិវាទអាពាហ៍ពិពាហ៍ ឬអាណាព្យាបាលភាពលើកូន។

---

[៥៤] បណ្ដឹងលេខ៣០១/១៩៨៨ រវាងR.M និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៦.៤

[៥៥] បណ្ដឹងលេខ៨១៩/១៩៩៨ រវាងKavanagh និងប្រទេសអៀកឡង់ កថាខ័ណ្ឌទី១០.៤

## IV. សច្ចធារណ៍នៃនិរទោស

៣០. យោងតាមមាត្រា១៤ កថាខណ្ឌទី២ ជនណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិទទួលបានការសន្មត់ជាមុនថាគ្មានទោស រហូតត្រូវបានបង្ហាញថាមានពិរុទ្ធភាពតាមច្បាប់។ សច្ចធារណ៍នៃនិរទោស ដែលជាមូលដ្ឋានគ្រឹះមួយក្នុងការការពារសិទ្ធិមនុស្ស ដាក់បន្ទុកលើអយ្យការឲ្យផ្តល់ភស្តុតាងពីបទចោទរបស់ខ្លួន។ សច្ចធារណ៍នេះ ធានាការពារថាគ្មានពិរុទ្ធភាពណាមួយអាចត្រូវបានសន្មត់ទុកជាមុននោះទេ ដរាបណាបទចោទ ត្រូវបានផ្តល់ភស្តុតាងលើសពីវិមតិសង្ស័យ ធានាថាជនជាប់ចោទទទួលបានប្រយោជន៍ពីវិមតិសង្ស័យ ហើយតំរូវថា ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌនោះ ត្រូវតែទទួលបានការប្រព្រឹត្តមកលើខ្លួន ស្របតាមគោលការណ៍នេះ។ អាជ្ញាធរសាធារណៈទាំងអស់ មានភារកិច្ចជៀសវាងពីការធ្វើបុរេវិនិច្ឆ័យលើលទ្ធផលនៃការជំនុំជម្រះ ឧ. ដោយមិនធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈដើម្បីបញ្ជាក់អះអាងពីពិរុទ្ធភាពរបស់ជនជាប់ចោទ។[៥៦] ជនជាប់ចោទ ជាធម្មតា ពុំគួរត្រូវបានដាក់ខ្នោះ ឬដាក់ក្នុងទ្រុងនៅកំឡុងពេលសវនាការឡើយ ឬបើពុំដូច្នោះទេ ត្រូវតែបង្ហាញដល់តុលាការ នៅក្នុងសភាពមួយដែលបញ្ជាក់ថា ពួកគេអាចជាឧក្រិដ្ឋ

---

[៥៦] បណ្តឹងលេខ៧៧០/១៩៩៧ រវាងGrindin និងសហព័ន្ធរុស្ស៊ី *កថាខណ្ឌទី៣.៥ និង៨.៣*

ជនប្រកបដោយគ្រោះថ្នាក់។ ប្រព័ន្ធផ្សព្វផ្សាយគួរជៀសវាងនូវការផ្សាយព័ត៌មានណាដែលធ្វើឲ្យអន្តរាយដល់សច្ចធារណ៍នៃនិរទោសនេះ។លើសពីនេះទៅទៀតរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នពុំគួរយកមកអនុវត្តធ្វើជាការចង្អុលបង្ហាញនៃពិរុទ្ធភាព និងកំរិតនៃទោសនោះទេ។[៥៧] ការបដិសេធមិនឲ្យដាក់ប្រាក់ធានានៅក្រៅឃុំ[៥៨] ឬការស្វែករកការទទួលខុសត្រូវនៅក្នុងនីតិវិធីរដ្ឋប្បវេណី[៥៩] ពុំប៉ះពាល់ដល់សច្ចធារណ៍នៃនិរទោសនោះទេ។

---

[៥៧] ស្តីពីទំនាក់ទំនងរវាងមាត្រា១៤ កថាខ័ណ្ឌទី២ និងមាត្រា៩ នៃកតិកាសញ្ញានេះ (ការឃុំខ្លួនបណ្តោះអាសន្ន) សូមមើលឧទាហរណ៍សេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអ៊ីតាលី CCPR/C/ITA/CO/5(2006), *កថាខ័ណ្ឌទី១៤* និងសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសអាហ្សង់ទីន CCPR/CO/70/ARG (2000), *កថាខ័ណ្ឌទី១០*។

[៥៨] បណ្តឹងលេខ៧៨៨/១៩៩៧ រវាង*Cagas, Butin and Astilleroនិងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៧.៣*។

[៥៩] បណ្តឹងលេខ២០៧/១៩៨៦ រវាង*Morael និងប្រទេសបារាំង កថាខ័ណ្ឌទី៩.៥*
*បណ្តឹងលេខ៤០៨/១៩៩០ រវាងW.J.H. និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.២*
*បណ្តឹងលេខ៤៣២/១៩៩០ រវាងW.B.E. និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.៦*។

## V. សិទ្ធិរបស់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ

៣១. សិទ្ធិរបស់ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌក្នុងការទទួលបានការជូនដំណឹងភ្លាមៗ និងលំអិត ក្នុងភាសាមួយដែលពួកគេយល់បានពីប្រភេទ និងបុព្វហេតុនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌដូចមានចែងក្នុងកថាខ័ណ្ឌទី៣(ក) គឺជាការធានាការពារជាអប្បបរមាដំបូងគេ នៅក្នុងដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌនៃមាត្រា១៤។ ការធានាការពារនេះ អនុវត្តចំពោះគ្រប់រឿងក្តីនៃបទចោទប្រកាន់ពីព្រហ្មទណ្ឌ រួមទាំងរឿងក្តីទាំងឡាយដែលជនជាប់ចោទ មិនស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នផង ប៉ុន្តែមិនអនុវត្តចំពោះការស៊ើបសួរព្រហ្មទណ្ឌ មុនការចោទប្រកាន់នោះទេ។[៦០] ការជូនដំណឹងអំពីមូលហេតុនៃការឃាត់ខ្លួន ត្រូវបានធានាការពារដាច់ដោយឡែក នៅក្នុងមាត្រា៩ កថាខ័ណ្ឌទី២ នៃកតិកាសញ្ញានេះ។[៦១] សិទ្ធិត្រូវបានជូនដំណឹង "ភ្លាមៗ" អំពីបទចោទប្រកាន់តំរូវថា ព័ត៌មានត្រូវបញ្ជូនទៅសាមីជននោះភ្លាមៗ បន្ទាប់ពីជននោះ ត្រូវបានចោទប្រកាន់ជាផ្លូវការពីបទល្មើសព្រហ្មទណ្ឌមួយ ក្រោមច្បាប់ជាតិ[៦២] ឬនៅពេលបុគ្គលនោះ ត្រូវបានបង្ហាញឈ្មោះជាសាធារណៈពីបទចោទនោះ។ លក្ខខណ្ឌតំរូវជាក់លាក់នៃអនុកថាខ័ណ្ឌទី៣(ក) អាច

---

[៦០] បណ្តឹងលេខ១០៥៦/២០០២ រវាង*Khachatrian និងប្រទេសអាមេនី កថាខ័ណ្ឌទី៦.៤។*

[៦១] បណ្តឹងលេខ២៥៣/១៩៨៧ *រវាងKelly និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៥.៨*

[៦២] បណ្តឹងលេខ១១២៨/២០០២ រវាង*Márques de Morais និងប្រទេសអង់ហ្គោឡា កថាខ័ណ្ឌទី៥.៤ និង*បណ្តឹងលេខ២៥៣/១៩៨៧ *រវាងKelly និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៥.៨ ។*

ត្រូវបានបំពេញ ដោយគូសបញ្ជាក់ពីបទចោទនោះដោយផ្ទាល់មាត់ក្ដី ប្រសិនបើក្រោយមកត្រូវបានបញ្ជាក់ជាលាយលក្ខណ៍អក្សរ ឬក៏គូសបញ្ជាក់ពីបទចោទនោះជាលាយលក្ខណ៍អក្សរតែម្ដង ឲ្យតែព័ត៌មាននោះ ចង្អុលបង្ហាញទាំងអង្គច្បាប់ និងអង្គហេតុទូទៅដែលបទចោទប្រកាន់នោះបានសំអាងលើ។ ក្នុងករណីនៃសវនាការកំបាំងមុខ មាត្រា១៤ កថាខ័ណ្ឌទី៣(ក) តំរូវថា ទោះបីជាអវត្តមានជនជាប់ចោទក៏ដោយ ក៏គ្រប់ដំណាក់ការនៃនីតិវិធី ត្រូវធ្វើឱ្យបានត្រឹមត្រូវ ដើម្បីជូនដំណឹងដល់ជនជាប់ចោទពីបទចោទប្រកាន់ និងជូនដំណឹងពួកគេ អំពីដំណើរការនីតិវិធី។[៦៣]

**៣២.** អនុកថាខ័ណ្ឌទី៣(ខ) ចែងថាជនជាប់ចោទត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនគេ។ បទប្បញ្ញត្តិនេះ គឺជាធាតុផ្សំមួយដ៏សំខាន់ នៃការធានាការពារសវនាការ ដោយយុត្តិធម៌ និងការអនុវត្តគោលការណ៍សមភាពនៃភាគីក្នុងរឿងក្ដី។[៦៤] នៅក្នុងករណីដែលជនជាប់ចោទក្រីក្រ ការទាក់ទងជាមួយមេធាវីអាចត្រូវបានធានា តែក្នុងករណីដែលត្រូវផ្ដល់អ្នកបកប្រែដោយឥតគិតថ្លៃ

---

[៦៣] បណ្ដឹងលេខ១៦/១៩៧៧ រវាង *Mbenge និងប្រទេសហ្សាអៀ កថាខ័ណ្ឌទី១៤.១*

[៦៤] បណ្ដឹងលេខ២៨២/១៩៨៨ រវាង *Smith និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១០.៤ បណ្ដឹងលេខ២២៦/១៩៨៧ និងបណ្ដឹងលេខ២៥៦/១៩៨៧ រវាងSawyers, Mclean និង Mclean និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១៣.៦។*

នៅកំឡុងពេលមុនសវនាការ និងពេលសវនាការប៉ុណ្ណោះ។[៦៥] អ្វីដែលចាត់ទុកថាជា "ពេលវេលាគ្រប់គ្រាន់" អាស្រ័យលើកាលៈទេសៈនៃរឿងក្ដីនីមួយៗ។ ប្រសិនបើ មេធាវីយល់ដោយសមហេតុផលថា ពេលវេលាសម្រាប់រៀបចំការពារមិនគ្រប់គ្រាន់ វាគឺជាភារកិច្ចរបស់ពួកគេក្នុងការស្នើពន្យាសវនាការ។[៦៦] រដ្ឋភាគីមិនត្រូវចាប់ឱ្យទទួលខុសត្រូវ ចំពោះការប្រព្រឹត្តរបស់មេធាវីការពារនោះទេ លុះត្រាតែវាត្រូវបាន ឬគួរតែត្រូវបានបង្ហាញដល់ចៅក្រមថា ឥរិយាបទរបស់មេធាវីនោះ មិនស្របនឹងផលប្រយោជន៍យុត្តិធម៌។[៦៧] តុលាការមានកាតព្វកិច្ចផ្ដល់ការយល់ស្រប តាមការស្នើសុំពន្យាសវនាការ ជាពិសេស នៅពេលដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយពេលវេលាបន្ថែមសម្រាប់រៀបចំការការពារក្ដី តម្រូវជាចាំបាច់។[៦៨]

---

[៦៥] សូមមើលបណ្ដឹងលេខ៤៥១/១៩៩១ រវាង*Harward និងប្រទេសណរវេស កថាខ័ណ្ឌទី៩.៥។*

[៦៦] បណ្ដឹងលេខ១១២៨/២០០២ រវាង*Morais និងប្រទេសអង់ហ្គោឡា កថាខ័ណ្ឌទី៥.៦។ ដូចគ្នានេះដែរ បណ្ដឹងលេខ៣៤៩/១៩៨៩ រវាង Wright និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៨.៤ ។*
*បណ្ដឹងលេខ២៧២/១៩៨៨ រវាង* Thomas *និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១១.៤*
*បណ្ដឹងលេខ២៣០/៨៧ រវាងHenry និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៨.២*
*បណ្ដឹងលេខ២២៦/១៩៨៧ និងបណ្ដឹងលេខ២៥៦/១៩៨៧ រវាងSawyers, Mclean* និង *Mclean និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១៣.៦។*

[៦៧] បណ្ដឹងលេខ១១២៨/២០០២ រវាង *Márques de Morais និងប្រទេសអង់ហ្គោឡា កថាខ័ណ្ឌទី៥.៤។*

[៦៨] បណ្ដឹងលេខ៩១៣/២០០០ រវាង*Chan និងប្រទេសហ្គុយយ៉ាណា កថាខ័ណ្ឌទី៦.៣។*
*បណ្ដឹងលេខ៥៩៤/១៩៩២ រវាងPhillip និងប្រទេសទ្រីនីដាត និងតូបាហ្គោ កថាខ័ណ្ឌទី៧.២។*

៣៣. "មធ្យោបាយគ្រប់គ្រាន់" ត្រូវរួមបញ្ចូលសិទ្ធិទទួលបានសំណុំរឿង និងភស្តុតាងផ្សេងៗ។ សិទ្ធិទទួលបាននេះត្រូវរួមបញ្ចូលគ្រប់ឯកសារសំភារៈ[៦៩] ដែលអយ្យការមានផែនការដាក់ជូនតុលាការប្រឆាំងនឹងជនជាប់ចោទឬជាភស្តុតាងដោះបន្ទុក។ឯកសារសំភារៈដោះបន្ទុក គួរត្រូវបានយល់ថា មានរួមបញ្ចូល មិនគ្រាន់តែឯកសារសំភារៈដែលបង្កើតពីភាពគ្មានទោសនោះទេ ប៉ុន្តែក៏ជាភស្តុតាងផ្សេងៗទៀតដែលអាចជួយដល់ជនជាប់ចោទ(ឧ.ការចង្អុលបញ្ជាក់ពីចម្លើយសារភាពដែលមិនបានធ្វើដោយស្ម័គ្រចិត្ត)។ ក្នុងករណីដែលមានការអះអាងថា ភស្តុតាងទទួលបាន ដោយរំលោភលើមាត្រា៧នៃកតិកាសញ្ញានេះ ព័ត៌មានជុំវិញកាលៈទេសៈនានាដែលភស្តុតាងបែបនេះទទួលបាន ត្រូវតែមាននៅក្នុងសំណុំរឿង ដើម្បីទុកលទ្ធភាពឱ្យមានការវាយតំលៃពីការអះអាងបែបនេះ។ ប្រសិនបើជនជាប់ចោទពុំនិយាយភាសាដែលប្រើប្រាស់នៅក្នុងដំណើរការនីតិវិធី ប៉ុន្តែត្រូវបានការពារដោយមេធាវីដែលចេះភាសានោះ គឺវាគ្រប់គ្រាន់ហើយ បើមេធាវីនោះបានទទួលឯកសារពាក់ព័ន្ធនានានៅក្នុងសំណុំរឿងនោះ។[៧០]

---

[៦៩] សូមមើលសេចក្តីសង្កេតសន្និដ្ឋានសំរាប់ប្រទេសកាណាដា, CCPR/C/CAN/CO/5 (2005), កថាខ័ណ្ឌទី១៣។

[៧០] បណ្តឹងលេខ៤៥១/១៩៩១ រវាង *Harward និងប្រទេសណរវេស កថាខ័ណ្ឌទី៩.៥។ បណ្តឹងលេខ៧៧០/១៩៩៧ រវាងGridin និងសហព័ន្ធរុស្ស៊ី កថាខ័ណ្ឌទី៨.៥។*

**៣៤.** សិទ្ធិប្រាស្រ័យទាក់ទងជាមួយមេធាវី តំរូវថា ជនជាប់ចោទត្រូវបានផ្តល់ឱ្យនូវសិទ្ធិទទួលបានមេធាវីភ្លាមៗ។ មេធាវីគួរតែអាចជួបកូនក្តីរបស់ខ្លួនក្នុងលក្ខណៈជាឯកជនបាន និងប្រាស្រ័យទាក់ទងជាមួយជនជាប់ចោទនោះ នៅក្នុងលក្ខខណ្ឌដែលគោរពបានទាំងស្រុង ដល់ការសម្ងាត់នៃការប្រាស្រ័យទាក់ទងគ្នានេះ។[៧១] លើសពីនេះទៀត មេធាវីគួរតែអាចផ្តល់ប្រឹក្សា និងធ្វើជាតំណាងជនដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌមួយ ស្របតាមក្រមវិជ្ជាជីវៈដែលត្រូវបានទទួលស្គាល់ជាទូទៅ ដោយគ្មានការរឹតត្បិត រងឥទ្ធិពលសម្ពាធ ឬការជ្រៀតជ្រែកដោយពុំត្រឹមត្រូវពីខាងណាមួយឡើយ។

**៣៥.** សិទ្ធិរបស់ជនជាប់ចោទត្រូវបានជំនុំជម្រះដោយគ្មានការពន្យាពេលមិនត្រឹមត្រូវ ដូចមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី៣(គ) មិនគ្រាន់តែត្រូវបានតាក់តែងឡើងដើម្បីបញ្ចៀសការរក្សាទុកជននានាយូរពេក នៅក្នុងស្ថានភាពមួយមិនប្រាកដប្រជា អំពីជោគវាសនារបស់ពួកគេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន និងមិនគ្រាន់តែធានាថា ការដកហូតសេរីភាពបែបនេះមិនត្រូវមានរយៈពេលយូរជាងភាពចាំបាច់ នៅក្នុងកាលៈទេសៈនៃរឿងក្តីជាក់លាក់នោះទេ ប៉ុន្តែក៏បម្រើដល់ផលប្រយោជន៍យុត្តិធម៌ផងដែរ។ អ្វីដែលសមហេតុផល ត្រូវតែធ្វើការវាយតំលៃ ក្នុងកាលៈទេសៈនៃរឿងក្តី

[៧១] បណ្តឹងលេខ១១១៧/២០០២ រវាង*Khomidova និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.៤ បណ្តឹងលេខ៩០៧/២០០០ រវាង Siragev និងប្រទេសអ៊ុយបេគីស្ថាន កថាខ័ណ្ឌទី៦.៣*

នីមួយៗ[៧២] ដោយពិចារណាជាចម្បង ពីភាពស្មុគស្មាញនៃរឿងក្តីនោះ ការប្រព្រឹត្តរបស់ជនជាប់ចោទ និងរបៀបដែលរឿងក្តីនោះត្រូវបានចាត់ការដោយអាជ្ញាធររដ្ឋបាល និងតុលាការ។ នៅក្នុងករណីនានា ដែលជនជាប់ចោទត្រូវបានតុលាការបដិសេធមិនឲ្យនៅក្រៅឃុំដោយដាក់ប្រាក់ធានា ពួកគេត្រូវតែទទួលបានការជំនុំជម្រះយ៉ាងឆាប់រហ័សបំផុត តាមដែលអាចធ្វើទៅបាន។[៧៣] ការធានាការពារនេះ ពាក់ព័ន្ធនឹង មិនត្រឹមតែពេលវេលារវាងការចោទប្រកាន់ជនជាប់ចោទជាផ្លូវការ និងពេលវេលាដែលការជំនុំជម្រះត្រូវចាប់ផ្តើមនោះទេ ប៉ុន្តែក៏ត្រូវពាក់ព័ន្ធនឹងពេលវេលារហូតដល់មានសាលដីកាស្ថាពរផងដែរ។[៧៤] នៅគ្រប់ដំណាក់កាល ទោះជា

---

[៧២] សូមមើលឧទាហរណ៍បណ្តឹងលេខ៨១៨/១៩៩៨ រវាងSextus *និងប្រទេសទ្រីណីដាត និងតូបាហ្គោ កថាខ័ណ្ឌទី៧.២ ស្តីពីការពន្យាពេល២២ខែ រវាងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋដែលត្រូវទទួលទោសប្រហារជីវិត និងការចាប់ផ្តើមសវនាការដោយពុំមានកាលៈទេសៈជាក់លាក់ដើម្បីផ្តល់យុត្តិកម្មចំពោះការពន្យាពេលនេះ។ នៅក្នុងបណ្តឹងលេខ៥៣៧/១៩៩៣ រវាង* Kelly *និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៥.១១ ការពន្យាពេល១៨ខែ រវាងការដាក់ការចោទប្រកាន់ និងការចាប់ផ្តើមសវនាការ ពុំបានរំលោភមាត្រា១៤ កថាខ័ណ្ឌទី៣ (គ)នោះទេ។ សូមមើលផងដែរ បណ្តឹងលេខ៦៧៦/១៩៩៦ រវាង* Yasseen & Thomas *និងប្រទេសហ្គីយ៉ាណា កថាខ័ណ្ឌទី៧.១១* (*ការពន្យាពេល២ឆ្នាំ រវាងសេចក្តីសម្រេចដោយសាលាឧទ្ធរណ៍ និងការចាប់ផ្តើមសវនាការម្តងទៀត) និងបណ្តឹងលេខ៩៣៨/២០០០ រវាង* Siewpersaud, Sukhram *និង* Persaud *និងប្រទេសទ្រីនីដាតនិងតូបាហ្គោ កថាខ័ណ្ឌទី៦.២ (រយៈពេលសរុបនៃដំណើរការនីតិវិធីស៊ីពេលស្ទើរតែ៥ឆ្នាំ ដោយពុំមានការពន្យល់ណាមួយពីរដ្ឋភាគីនោះ ដើម្បីផ្តល់យុត្តិកម្មចំពោះការពន្យាពេលនោះទេ)។*

[៧៣] បណ្តឹងលេខ៨១៨/១៩៩៨ រវាង*Sextus និងប្រទេសទ្រីនីដាតនិងតូបាហ្គោ កថាខ័ណ្ឌទី៧.២។*

[៧៤] បណ្តឹងលេខ១០៨៩/២០០២ រវាង*Rouse និងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៧.៤*

*បណ្តឹងលេខ១០៨៥/២០០២ រវាងTaright, Touadi Remli និង Yousfi និងប្រទេសអាល់ហ្សេរី កថាខ័ណ្ឌទី៨.៥។*

នៅសាលាដំបូង ឬនៅសាលាឧទ្ធរណ៍ត្រូវតែប្រព្រឹត្តទៅ "ដោយគ្មានការពន្យាពេលមិនត្រឹមត្រូវ" ឡើយ។

**៣៦.** មាត្រា១៤ កថាខ័ណ្ឌទី៣$_{(ឃ)}$ មានការធានាការពារបីខុសៗគ្នា។ ទី១ បទប្បញ្ញត្តិនេះតំរូវថា ជនជាប់ចោទមានសិទ្ធិមានវត្តមាននៅក្នុងសវនាការជំនុំជម្រះក្តីខ្លួន។ នៅក្នុងកាលៈទេសៈមួយចំនួនដំណើរការនីតិវិធីដោយកំបាំងមុខជនជាប់ចោទ អាចត្រូវបានអនុញ្ញាត ដើម្បីជាប្រយោជន៍ដល់រដ្ឋបាលត្រឹមត្រូវនៃយុត្តិធម៌ ឧ. នៅពេលដែលជនជាប់ចោទ បោះបង់ការអនុវត្តសិទ្ធិមានវត្តមានរបស់ខ្លួន ទោះបីជាត្រូវបានជូនដំណឹងគ្រប់គ្រាន់ជាមុនពីដំណើរការនីតិវិធីក៏ដោយ។ ហេតុនេះហើយ សវនាការបែបនេះគឺស្របនឹងមាត្រា១៤ កថាខ័ណ្ឌទី៣$_{(ឃ)}$ តែក្នុងករណីដែលវិធានការចាំបាច់នានាត្រូវបានអនុវត្ត ដើម្បីកោះហៅជនជាប់ចោទ តាមពេលវេលាមួយសមស្រប និងជូនដំណឹងដល់ពួកគេជាមុនអំពីកាលបរិច្ឆេទ និងទីកន្លែងនៃសវនាការជំនុំជម្រះក្តីពួកគេ និងស្នើសុំឲ្យពួកគេចូលខ្លួន។[៧៥]

**៣៧.** ទីពីរ សិទ្ធិរបស់ជនជាប់ចោទគ្រប់រូប ដែលត្រូវជាប់ចោទពីបទព្រហ្មទណ្ឌ ដើម្បីការពារខ្លួនដោយខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានទទួលដំណឹងអំពីសិទ្ធិនេះ ដូចមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី៣$_{(ឃ)}$ សំដៅ

[៧៥] បណ្តឹងលេខ១៦/១៩៧៧ រវាង*Mbenge និងប្រទេសហ្សាអៀ កថាខ័ណ្ឌទី១៤.១*
*បណ្តឹងលេខ៦៩៩/១៩៩៦ រវាងMaleki និងប្រទេសអ៊ីតាលី កថាខ័ណ្ឌទី៩.៣។*

លើការការពារពីរប្រភេទដែលមិនអាចចែកដាច់ពីគ្នាទៅវិញទៅមកបាននោះទេ។ បុគ្គលដែលទទួលបានជំនួយពីមេធាវីមានសិទ្ធិប្រាប់ទៅមេធាវីរបស់ខ្លួន អំពីចំណាត់ការនៃរឿងក្ដីរបស់ខ្លួន ក្នុងកំរិតនៃការទទួលខុសត្រូវខាងវិជ្ជាជីវៈ និងផ្ដល់សក្ខីកម្មជំនួសខ្លួន។ ទន្ទឹមនឹងនោះ ពាក្យពេចន៍នៃកតិកាសញ្ញានេះ មានលក្ខណៈច្បាស់លាស់ នៅគ្រប់ភាសាផ្លូវការ ដែលចែងថាការការពារខ្លួនដោយខ្លួនឯង "ឬ" តាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន។ ដូច្នោះ បទប្បញ្ញត្តិនេះផ្ដល់លទ្ធភាពឲ្យជនជាប់ចោទ បដិសេធមិនទទួលយកជំនួយការច្បាប់ណាមួយ។ ទោះបីយ៉ាងណាក៏ដោយ សិទ្ធិការពារខ្លួនដោយខ្លួនឯង ដោយគ្មានមេធាវី ពុំមានលក្ខណៈដាច់ខាតនោះទេ។ ក្នុងករណីនៃការជំនុំជម្រះជាក់លាក់មួយ ផលប្រយោជន៍យុត្តិធម៌ អាចតំរូវឲ្យមានការចាត់តាំងមេធាវីប្រឆាំងនឹងឆន្ទៈរបស់ជនជាប់ចោទ ជាពិសេស ក្នុងករណីដែលជនជាប់ចោទនោះ បង្កការរាំងស្ទះជាសារវ័ន្ត និងម្ដងហើយម្ដងទៀត ដល់ការប្រព្រឹត្តទៅដ៏ត្រឹមត្រូវនៃការជំនុំជម្រះ ឬប្រឈមនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ ប៉ុន្តែមិនអាចការពារផលប្រយោជន៍របស់ខ្លួនបាន ឬក្នុងករណីចាំបាច់ ដើម្បីការពារសាក្សីដែលងាយរងគ្រោះពីការរុកគួន ឬការបំភិតបំភ័យបន្ថែមទៀត ប្រសិនបើពួកគេត្រូវបានសាកសួរដោយជនជាប់ចោទ។ ទោះជាដូច្នេះក៏ដោយ ការរឹតត្បិតណាមួយលើឆន្ទៈរបស់ជនជាប់ចោទ ដើម្បីការពារខ្លួនដោយខ្លួន

ឯង ត្រូវតែមានគោលដៅ និងគោលបំណងគ្រប់គ្រាន់ធួនល្មម និងមិនត្រូវទៅហួសពីអ្វីដែលជាភាពចាំបាច់ ដើម្បីតំកល់ប្រយោជន៍យុត្តិធម៌នោះទេ។ ហេតុដូច្នេះហើយ ច្បាប់ជាតិគួរតែជៀសវាងនូវការហាមឃាត់ដាច់ខាតណាមួយ ប្រឆាំងនឹងសិទ្ធិការពារខ្លួនដោយខ្លួនឯង នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយពុំមានជំនួយពីមេធាវី។[៧៦]

**៣៨.** ទីបី មាត្រា១៤ កថាខ័ណ្ឌទី៣(ឃ) ធានាការពារសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ ដែលត្រូវផ្តល់ឲ្យជនជាប់ចោទ នៅពេលណាដែលប្រយោជន៍យុត្តិធម៌តំរូវយ៉ាងដូច្នេះ និងដោយពុំយកកំរៃពីពួកគេ នៅក្នុងករណីបែបនេះ ប្រសិនបើពួកគេ ពុំមានលទ្ធភាពគ្រប់គ្រាន់បង់ថ្លៃទេនោះ។ ភាពធ្ងន់ធ្ងរនៃបទល្មើសមានសារសំខាន់ក្នុងការសម្រេចថាតើជំនួយការច្បាប់គួរត្រូវបានចាត់តាំង ឬអត់ "ដើម្បីជាប្រយោជន៍យុត្តិធម៌"[៧៧] ដោយសារថា នោះគឺជាអត្ថិភាពនៃឱកាសជាក់លាក់មួយចំនួននៃជ័យជំនះនៅដំណាក់កាលឧទ្ធរណ៍។[៧៨] ក្នុងករណីនានាដែលពាក់ព័ន្ធនឹងទោសប្រហារជីវិតវាគឺជាការពិតដែលថា ជនជាប់ចោទ ត្រូវតែទទួលបានជំនួយផ្នែកច្បាប់ យ៉ាងមាន

---

[៧៦] បណ្តឹងលេខ១១២៣/២០០២ រវាង*Correia de Matos និងប្រទេសព័រទុយហ្គាល់ កថាខ័ណ្ឌទី៧.៤ និងកថាខ័ណ្ឌទី៧.៥។*

[៧៧] បណ្តឹងលេខ៦៤៦/១៩៩៥ រវាង*Lindon និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៦.៥។*

[៧៨] បណ្តឹងលេខ៣១៤/១៩៨៨ រវាង*Z.P. និងប្រទេសកាណាដា កថាខ័ណ្ឌទី៥.៤។*

ប្រសិទ្ធភាពពីមេធាវីនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។[៧៩] ជំនួយការច្បាប់ដែលផ្តល់ឲ្យដោយអាជ្ញាធរមានសមត្ថកិច្ច ដោយឈរលើមូលដ្ឋាននៃបទប្បញ្ញត្តិនេះ ត្រូវតែមានប្រសិទ្ធភាពក្នុងការតំណាងឱ្យជនជាប់ចោទ។ មិនដូចក្នុងករណីនៃមេធាវីដែលជ្រើសរើសដោយខ្លួនឯងនោះទេ[៨០] *ការប្រព្រឹត្តខុស ឬអសមត្ថភាពជាក់ស្តែង* ឧ. ការដកបណ្តឹងឧទ្ធរណ៍ ដោយគ្មានពិគ្រោះយោបល់ក្នុងករណីទោសប្រហារជីវិត[៨១] ឬអវត្តមាននៅកំឡុងពេលសវនាការសួរដេញដោលសាក្សីក្នុងករណីបែបនេះ[៨២] អាចតម្រូវឱ្យមានការទទួលខុសត្រូវពីរដ្ឋសាមីចំពោះការបំពានលើមាត្រា១៤ កថាខ័ណ្ឌទី៣(ឃ) ឲ្យតែករណីនេះត្រូវបានបង្ហាញជូនចៅក្រមថា ការប្រព្រឹត្តរបស់មេធាវីនោះ មិនស្របនឹងប្រយោជន៍យុត្តិធម៌។[៨៣] ក៏ជាការ

---

[៧៩] បណ្តឹងលេខ៩៨៥/២០០២ រវាង*Aliboeva និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.៤*
*បណ្តឹងលេខ៩៦៤/២០០១ រវាងSaidova និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.៨*
*បណ្តឹងលេខ៧៨១/១៩៩៧ រវាងAliev និងប្រទេសអ៊ុយក្រែន កថាខ័ណ្ឌទី៧.៣*
*បណ្តឹងលេខ៥៥៤/១៩៩៣ រវាងLaVande និងប្រទេសទ្រីនីដាត និងតូបាហ្គោ កថាខ័ណ្ឌទី៥៨*

[៨០] បណ្តឹងលេខ៣៨៣/១៩៨៩ រវាង*H.C. និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៦.៣។*

[៨១] បណ្តឹងលេខ២៥៣/១៩៨៧ រវាង*Kelly និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៩.៥។*

[៨២] បណ្តឹងលេខ៨៣៨/១៩៩៨ រវាង*Hedricks និងប្រទេសហ្គីយាណា កថាខ័ណ្ឌទី៦.៤។* សម្រាប់ករណីនៃអវត្តមានរបស់តំណាងផ្លូវច្បាប់នៃម្ចាស់បណ្តឹង ក្នុងកំឡុងសវនាការសួរដេញដោលសាក្សីពេលសវនាការបឋម សូមមើលបណ្តឹងលេខ៧៧៥/១៩៩៧ រវាង*Brown និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៦.៦។*

[៨៣] បណ្តឹងលេខ៧០៥/១៩៩៦ រវាង*Taylor និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៦.២*
*បណ្តឹងលេខ៩១៣/២០០០ រវាងChan និងប្រទេសហ្គីយាណា កថាខ័ណ្ឌ៦.២*
*បណ្តឹងលេខ៩៨០/២០០១ រវាងHussain និងប្រទេសកោះម៉ូរីស កថាខ័ណ្ឌទី៦.៣។*

បំពានលើបទប្បញ្ញត្តិនេះផងដែរ ប្រសិនបើតុលាការ ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត រារាំងមេធាវីដែលត្រូវបានតែងតាំង មិនឲ្យបំពេញកិច្ចការរបស់ខ្លួនបានដោយប្រសិទ្ធភាព។[៨៤]

**៣៩.** កថាខ័ណ្ឌទី៣(ង) នៃមាត្រា១៤ ធានាការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការសាកសួរ ឬឲ្យមានការសួរដេញដោលសាក្សីដាក់បន្ទុក ព្រមទាំងទទួលបានការចូលរួម និងការសាកសួរសាក្សីដោះបន្ទុក ក្រោមលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ។ ដូចជាការអនុវត្តគោលការណ៍សមភាពនៃភាគីនៅក្នុងរឿងក្ដី ការធានាការពារនេះ មានសារៈសំខាន់ដល់ការធានាឱ្យមានការការពារដ៏មានប្រសិទ្ធភាពដោយជនជាប់ចោទ និងជំនួយការច្បាប់របស់ពួកគេ ហើយនេះគឺជាការធានាការពារជនជាប់ចោទ ឱ្យមានអំណាចតាមផ្លូវច្បាប់ ដូចគ្នានឹងអំណាចដែលអយ្យការមានដែរ ក្នុងការបង្គាប់ឲ្យមានការចូលខ្លួនរបស់សាក្សី សាកសួរ ឬសួរដេញដោលសាក្សីណាមួយ។ ទោះជាដូច្នោះក៏ដោយ ក៏គោលការណ៍នេះពុំផ្ដល់សិទ្ធិឥតព្រំដែនក្នុងការទទួលបានការចូលរួមពីសាក្សីណាមួយ តាមការស្នើសុំរបស់ជនជាប់ចោទ ឬជំនួយការច្បាប់របស់គេនោះទេ ប៉ុន្តែគ្រាន់តែជាសិទ្ធិមានសាក្សី ដែលត្រូវទទួលយក នៅក្នុងសំណុំរឿង ហើយដែលសមស្របសម្រាប់ការការពារក្ដីខ្លួន ហើយត្រូវទទួលបានកាលានុវត្តភាពត្រឹមត្រូវដើម្បីតាំងសំនួរ និងសួរតតាំងសាក្សី

[៨៤] បណ្ដឹងលេខ៩១៧/២០០០ រវាង*Arutyunyan និងប្រទេសអ៊ុយបេគីស្ថាន កថាខ័ណ្ឌទី៦.៣។*

ដាក់បន្ទុកនៅដំណាក់កាលមួយចំនួននៃដំណើរការនីតិវិធី។ ស្ថិតក្នុងព្រំដែនកំណត់ទាំងនេះ និងស្ថិតក្រោមការដាក់កំរិតលើការប្រើប្រាស់កំណត់ហេតុយកចំលើយ ចម្លើយសារភាព និងភស្តុតាងផ្សេងទៀតដែលទទួលបានដោយបំពាននឹងមាត្រា៧[៨៥] ដំបូងបំផុតគឺអាស្រ័យលើច្បាប់ជាតិរបស់រដ្ឋភាគីដើម្បីកំណត់ពីការទទួលយកភស្តុតាងនិងអំពីរបៀបដែលតុលាការវាយតំលៃភស្តុតាងទាំងនេះ។

៤០. សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែដោយឥតគិតថ្លៃក្នុងករណីដែលជនជាប់ចោទនោះពុំអាចយល់ ឬនិយាយភាសាដែលប្រើប្រាស់នៅក្នុងតុលាការ ដូចមានចែងក្នុងមាត្រា១៤ កថាខ័ណ្ឌទី៣(ច) មានចែងពីទិដ្ឋភាពមួយទៀតនៃគោលការណ៍ភាពត្រឹមត្រូវនិងសមភាពនៃភាគីក្នុងរឿងក្តីនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។[៨៦] សិទ្ធិនេះត្រូវផ្តល់ឲ្យនៅគ្រប់ដំណាក់កាល នៃដំណើរការនីតិវិធីផ្ទាល់មាត់។ គោលការណ៍នេះ អនុវត្តចំពោះជនបរទេសដូចគ្នានឹងប្រជាពលរដ្ឋនៃរដ្ឋសាមីដែរ។ ទោះជាដូច្នោះក៏ដោយ ជនជាប់ចោទដែលមានភាសាកំណើត ខុសពីភាសាផ្លូវការដែលប្រើប្រាស់ក្នុងតុលាការ ជាគោលការណ៍ ពុំត្រូវបានផ្តល់សិទ្ធិឲ្យទទួលបានអ្នកបកប្រែដោយឥតគិតថ្លៃនោះទេ ប្រសិនបើពួកគេចេះភាសាផ្លូវការនោះគ្រប់គ្រាន់ដើម្បីនឹងការពារខ្លួនឯងបានដោយប្រសិទ្ធភាពហើយនោះ។[៨៧]

---

[៨៥] សូមមើលកថាខ័ណ្ឌទី៦ ខាងលើ។

[៨៦] បណ្តឹងលេខ២១៩/១៩៨៦ រវាង*Guesdon និងប្រទេសបារាំង កថាខ័ណ្ឌទី១០.២។*

[៨៧] សូមមើលពីខាងលើ។

៤១. ជាទីបញ្ចប់ មាត្រា១៤ កថាខ័ណ្ឌទី៣(ឆ) ធានាការពារសិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯងឬសារភាពថាមានពិរុទ្ធ។ ការធានាការពារនេះ ត្រូវបានយល់ក្នុងន័យនៃការមិនដាក់សម្ពាធដោយផ្ទាល់ ឬដោយប្រយោលលើផ្លូវកាយ ឬផ្លូវចិត្ត ដោយមិនត្រឹមត្រូវពីអាជ្ញាធរស៊ើបអង្កេតលើជនជាប់ចោទដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពនោះឡើយ ជាមួយនឹងហេតុផលរឹងមាំ ការប្រព្រឹត្តលើជនជាប់ចោទក្នុងលក្ខណៈផ្ទុយនឹងមាត្រា៧ នៃកតិកាសញ្ញានេះ ដើម្បីទាញយកចម្លើយសារភាពមិនអាចទទួលយកបាននោះទេ។[៨៨] ច្បាប់ជាតិត្រូវតែធានាថា កំណត់ហេតុយកចំលើយឬចម្លើយសារភាពដែលទទួលបានដោយបំពាននឹងមាត្រា៧ នៃកតិកាសញ្ញានេះ ត្រូវបានផាត់ចេញពីភស្តុតាង លើកលែងតែក្នុងករណីដែលឯកសារបែបនោះ ត្រូវបានប្រើប្រាស់ជាភស្តុតាងថា អំពើទារុណកម្ម ឬការប្រព្រឹត្តមិនគប្បីផ្សេងទៀត ដែលត្រូវបានហាមឃាត់ដោយបទប្បញ្ញត្តិនេះ បានកើតមាន[៨៩] ហើយថានៅក្នុងករណីបែបនេះ រដ្ឋត្រូវមានបន្ទុកផ្តល់ភស្តុតាងថា កំណត់ហេតុយកចំលើយពីជនជាប់ចោទ ត្រូវបានធ្វើទៅតាមឆន្ទៈដោយសេរីរបស់ជនជាប់ចោទផ្ទាល់។[៩០]

---

[៨៨] បណ្តឹងលេខ១២០៨/២០០៣ រវាង*Kurbonov និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.២-៦.៤*
*បណ្តឹងលេខ១០៤៤/២០០២ រវាងShukurova និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៨.២*
*បណ្តឹងលេខ១០៣៣/២០០១ រវាងSingarasa និងប្រទេសស្រីលង្កា កថាខ័ណ្ឌទី៧.៤*
*បណ្តឹងលេខ៩១២/២០០០ រវាងDeolall និងប្រទេសហ្គីយាណា កថាខ័ណ្ឌទី៥.១*
*បណ្តឹងលេខ២៥៣/១៩៨៧ រវាងKelly និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៥.៥។*

[៨៩] សូមមើលអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប មាត្រា១៥។ ចំពោះការប្រើប្រាស់ភស្តុតាងដទៃ ទៀត ដែលទទួលបានដោយរំលោភនឹងមាត្រា៧ នៃកតិកាសញ្ញានេះ សូមមើលកថាខ័ណ្ឌទី៦ខាងលើ។

[៩០] បណ្តឹងលេខ១០៣៣/២០០១ រវាង*Singarasa* និងប្រទេសស្រីលង្កា កថាខ័ណ្ឌទី៧.៤
បណ្តឹងលេខ២៥៣/១៩៨៧ រវាង*Kelly និងប្រទេសចាម៉ៃកា* កថាខ័ណ្ឌទី៧.៤។

## VI. អនីតិជន

៤២. មាត្រា១៤ កថាខណ្ឌទី៤ ចែងថានៅក្នុងរឿងក្តីអនីតិជន នីតិវិធីគួរតែពិចារណាលើអាយុរបស់ពួកគេ និងតម្រូវការលើកស្ទួយការស្តារនីតិសម្បទារបស់ពួកគេ។ អនីតិជនត្រូវទទួលបាន យ៉ាងហោចណាស់ ក៏ការធានានិងកិច្ចការពារដូចត្រូវបានផ្តល់ឱ្យនីតិជនក្រោមមាត្រា១៤ នៃកតិកាសញ្ញានេះ។ លើសពីនេះទៀត អនីតិជនត្រូវការកិច្ចការពារពិសេស។ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនិយាយដោយឡែក អនីតិជនគួរត្រូវបានជូនដំណឹងដោយផ្ទាល់ពីការចោទប្រកាន់ចំពោះគេ និងប្រសិនបើសមស្រប តាមរយៈឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។ អនីតិជន គួរត្រូវបានផ្តល់ជំនួយសមស្របក្នុងការរៀបចំការពារខ្លួន គួរត្រូវបានជំនុំជម្រះ ឱ្យបានឆាប់តាមតែអាចធ្វើបាន ក្នុងសវនាការមួយត្រឹមត្រូវនៅចំពោះមុខវត្តមានមេធាវី ជំនួយសមស្របដទៃទៀត និងឪពុក-ម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់គេ លុះត្រាតែទង្វើនោះត្រូវបានចាត់ទុកថា មិនបម្រើឲ្យឧត្តមប្រយោជន៍របស់កុមារ ជាពិសេស ត្រូវពិចារណាលើអាយុ ឬស្ថានភាពរបស់គេ។ ការឃុំខ្លួនបណ្តោះអាសន្ន គួរតែត្រូវជៀសវាងឲ្យអស់ពីលទ្ធភាពបំផុត។[៩១]

[៩១] សូមមើលសេចក្តីពន្យល់ទូទៅលេខ១៧(១៩៨៩) ស្តីពីមាត្រា២៤ (សិទ្ធិកុមារ) កថាខណ្ឌទី៤។

៤៣. រដ្ឋគួរតែចាត់វិធានការនានា ដើម្បីបង្កើតប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនីតិជនដ៏សមស្របមួយ ដើម្បីធានាថា អនីតិជនត្រូវបានប្រព្រឹត្តលើក្នុងលក្ខណៈមួយ ដែលសមមាត្រគ្នានឹងអាយុរបស់គេ។ ការកំណត់អាយុក្រោមអប្បបរមាសំរាប់កុមារ និងអនីតិជនមិនត្រូវយកទៅជំនុំជម្រះពីបទល្មើសព្រហ្មទណ្ឌ មានសារៈសំខាន់ណាស់។ អាយុនោះ គួរតែត្រូវពិចារណាលើភាពចាស់ទុំខាងរាងកាយ និងផ្លូវចិត្តរបស់ពួកគេ។

៤៤. នៅពេលណាសមស្រប ជាពិសេសក្នុងករណីដែលការស្តារនីតិសម្បទាអនីតិជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ គួរតែត្រូវបានលើកតម្កើង ហើយវិធានការនានាក្រៅពីដំណើរការនីតិវិធីព្រហ្មទណ្ឌ ដូចជាការសម្រុះសម្រួលរវាងជនល្មើស និងជនរងគ្រោះ ការពិភាក្សាជាមួយក្រុមប្រឹក្សាញាត្តរបស់ជនល្មើស ការផ្តល់ប្រឹក្សាយោបល់ ឬការបម្រើសហគមន៍ ឬការដាក់ឲ្យស្ថិតក្រោមកម្មវិធីអប់រំ គួរត្រូវបានយកមកពិចារណា ឱ្យតែវិធានការទាំងនោះ ស្របនឹងលក្ខខណ្ឌតំរូវនៃកតិកាសញ្ញានេះ និងបទដ្ឋានសិទ្ធិមនុស្សពាក់ព័ន្ធដទៃទៀត។

## VII. ការពិនិត្យឡើងវិញដោយសាលាជម្រះក្តីជាន់ខ្ពស់

**៤៥.**មាត្រា១៤ កថាខ័ណ្ឌទី៥នៃកតិកាសញ្ញានេះចែងថាជនណាក៏ដោយ ដែលត្រូវបានផ្តន្ទាទោសពីបទព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឲ្យសាលាជម្រះក្តីជាន់ខ្ពស់ ពិនិត្យឡើងវិញទៅលើការផ្តន្ទាទោស និងការកាត់ទោសនេះស្របតាមច្បាប់។ ដូចដែលការប្រើប្រាស់វាក្យស័ព្ទខុសៗគ្នា បង្ហាញការធានាការពារ មិនកំរិតត្រឹមតែបទល្មើសធ្ងន់ធ្ងរបំផុតនោះទេ។ ឃ្លា "ស្របតាមច្បាប់" នៅក្នុងបទប្បញ្ញត្តិនេះ ពុំមានន័យថាសិទ្ធិសុំឲ្យពិនិត្យឡើងវិញនេះជាឆន្ទានុសិទ្ធិរបស់រដ្ឋភាគីនោះទេ ដោយសារតែសិទ្ធិនេះ ត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញានេះ និងមិនត្រឹមតែដោយច្បាប់ជាតិនោះទេ។ វាក្យស័ព្ទនេះ អនុលោមតាមច្បាប់ ជាជាងទាក់ទិននឹងការកំណត់ពីបែបបទ ដែលត្រូវយកទៅអនុវត្តក្នុងការពិនិត្យឡើងវិញ ដោយសាលាជំនុំជម្រះក្តីជាន់ខ្ពស់[៩២] និងតុលាការណាទទួលខុសត្រូវអនុវត្តការពិនិត្យឡើងវិញនេះ អនុលោមតាមកតិកាសញ្ញានេះ។ មាត្រា១៤ កថាខ័ណ្ឌទី៥ ពុំតំរូវឲ្យរដ្ឋភាគី ត្រូវផ្តល់ឱ្យមានបណ្តឹងទៅតុលាការជាន់ខ្ពស់ជាច្រើនដងច្រើនថ្នាក់នោះទេ។[៩៣] ទោះជាដូច្នេះក៏ដោយ ការយោងទៅរកច្បាប់ជាតិក្នុងបទប្បញ្ញត្តិនេះត្រូវបកស្រាយក្នុងអត្ថន័យថា ប្រសិនបើច្បាប់ជាតិផ្តល់ឱ្យមានបណ្តឹងបែបនេះ នោះជនជាប់ចោទត្រូវមានសិទ្ធិទទួលបានដោយប្រសិទ្ធភាព នូវសិទ្ធិធ្វើបណ្តឹងបែបនេះ។[៩៤]

---

[៩២] បណ្តឹងលេខ១០៩៥/២០០២ រវាង*Gomariz Valera និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៧.១ និងបណ្តឹងលេខ៦៤/១៩៧៩ រវាងSalgar de Montejo និងប្រទេសកូឡុំប៊ី កថាខ័ណ្ឌទី១០.៤។*

[៩៣] បណ្តឹងលេខ១០៨៩/២០០២ រវាង*Rouse និងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៧.៦។*

[៩៤] បណ្តឹងលេខ២៣០/១៩៨៧ រវាង*Henry និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៨.៤។*

៤៦. មាត្រា១៤ កថាខ័ណ្ឌទី៥ មិនអនុវត្តចំពោះនីតិវិធីក្នុងការកំណត់ពីសិទ្ធិ និងកាតព្វកិច្ចនៅក្នុងបណ្តឹងតាមផ្លូវច្បាប់ឡើយ[៩៥] ឬនីតិវិធីផ្សេងទៀត ដែលពុំមែនជាផ្នែកនៃដំណើរការបណ្តឹងឧទ្ធរណ៍ ក្នុងរឿងព្រហ្មទណ្ឌទេ ដូចជាញ្ញត្តប្តឹងពីធម្មនុញ្ញភាពជាដើម។[៩៦]

៤៧.មាត្រា១៤ កថាខ័ណ្ឌទី៥ ត្រូវបានបំពានមិនត្រឹមតែនៅក្នុងករណីដែលការសម្រេចរបស់សាលាដំបូង ចូលជាធរមាននោះទេ ប៉ុន្តែក៏នៅក្នុងករណីដែលពិរុទ្ធភាពត្រូវបានប្រកាសដោយសាលាឧទ្ធរណ៍[៩៧] ឬដោយតុលាការមួយដែលបិតផ្លូវតវ៉ាផងដែរ[៩៨] បន្ទាប់ពីការសម្រេចឲ្យរួចខ្លួនដោយតុលាការជាន់ទាបមួយស្របតាមច្បាប់ជាតិនោះ មិនអាចត្រូវបានពិនិត្យឡើងវិញ ដោយតុលាការជាន់ខ្ពស់មួយនោះទេ។ នៅក្នុងករណីដែលតុលាការកំពូលនៃប្រទេសមួយ ដើរតួនាទីជាសាលាដំបូងផង ជាតុលាការតែមួយថ្នាក់ផង គេមិនត្រូវសន្មត់ថា សិទ្ធិសុំឲ្យពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់ ត្រូវបានអនុវត្តរួច ដោយសំអាងហេតុថារឿងក្តីនោះ ត្រូវបានជំនុំជម្រះដោយតុលាការកំពូលនៃរដ្ឋភាគីសាមីនោះ រួចហើយនោះទេ ផ្ទុយទៅវិញប្រព័ន្ធបែបនេះមិនស្របនឹងកតិកាសញ្ញានេះឡើយ ប្រសិនបើរដ្ឋនេះ ពុំបានដាក់ខលក្ខខណ្ឌលើសិទ្ធិតាមបទប្បញ្ញត្តិនេះ។[៩៩]

---

[៩៥] បណ្តឹងលេខ៤៥០/១៩៩១ រវាង *I.P. និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី៦.២។*

[៩៦] បណ្តឹងលេខ៣៥២/១៩៨៩ រវាង *Douglas, Gentles, Kerr និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១១.២។*

[៩៧] បណ្តឹងលេខ១០៩៥/២០០២ រវាង *Gomariz Valera និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៧.១។*

[៩៨] បណ្តឹងលេខ១០៧៣/២០០២ រវាង *Terrón និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៧.៤។*

[៩៩] សូមមើលពីខាងលើ។

៤៨. សិទ្ធិទទួលបានការពិនិត្យឡើងវិញពីការផ្តន្ទាទោស និងការកាត់ទោសរបស់ខ្លួនដោយតុលាការជាន់ខ្ពស់មួយដែលបង្កើតឡើងតាមមាត្រា១៤ កថាខ័ណ្ឌទី៥ ដាក់កាតព្វកិច្ចលើរដ្ឋភាគីឲ្យពិនិត្យឡើងវិញយ៉ាងស៊ីជំរៅ ទាំងមូលដ្ឋាននៃភាពគ្រប់គ្រាន់របស់ភស្តុតាង និងអង្គច្បាប់ ទាំងការផ្តន្ទាទោសនិងការកាត់ទោស ដែលនីតិវិធីនោះអនុញ្ញាតឲ្យមានការពិចារណាយ៉ាងត្រឹមត្រូវ អំពីចរិតលក្ខណៈនៃរឿងក្តីនោះ។[១០០] ការពិនិត្យឡើងវិញមួយ ដែលត្រូវបានកំរិតត្រឹមអង្គច្បាប់នៃការផ្តន្ទាទោសដោយពុំពិចារណាលើអង្គហេតុណាមួយទាល់តែសោះនោះគឺមិនគ្រប់គ្រាន់តាមកតិកាសញ្ញានេះឡើយ។[១០១] ទោះជាដូច្នោះក៏ដោយ មាត្រា១៤ កថាខ័ណ្ឌទី៥ ពុំតំរូវឲ្យមានការជំនុំជម្រះឡើងវិញទាំងស្រុង ឬបើក "សវនាការ" ទាំងស្រុងនោះទេ ដរាបណាសាលាជម្រះក្តីដែលអនុវត្តការពិនិត្យឡើងវិញនោះ អាចពិនិត្យមើលលើទិដ្ឋភាពអង្គហេតុនៃរឿងក្តីនោះ។[១០២] ហេតុដូច្នោះ

---

[១០០] បណ្តឹងលេខ១១០០/២០០២រវាង *Bandajevsky* និងប្រទេសបែលឡារូស កថាខ័ណ្ឌទី១០.១៣ *បណ្តឹងលេខ៩៨៥/២០០១ រវាងAliboeva និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.៥ បណ្តឹងលេខ៩៧៣/២០០១ រវាងKhalilova និងប្រទេសតាក់ជីគីស្ថាន កថា ខ័ណ្ឌទី៧.៥ បណ្តឹងលេខ៦២៣-៦២៧/១៩៩៥ រវាងDomukovsky et al. និងប្រទេសហ្សកហ្ស៊ី កថាខ័ណ្ឌទី១៨.១១ បណ្តឹងលេខ៩៦៤/២០០១ រវាងSaidova និង ប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៦.៥ បណ្តឹងលេខ៨០២/១៩៩៨ រវាងRogerson និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.៥ និង បណ្តឹងលេខ៦៦២/១៩៩៥ រវាងLumley និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៣។*

[១០១] បណ្តឹងលេខ៧០១/១៩៩៦ រវាង *Gómez Vázquez និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី១១.១*

[១០២] បណ្តឹងលេខ៧០១/២០០២ រវាង *Rolando និងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៤.៥ បណ្តឹងលេខ៩៨៤/២០០១ រវាងJuma និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៧.៥ បណ្តឹងលេខ៥៣៦/១៩៩៣ រវាងPerera និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៦.៤។*

ឱ. ក្នុងករណីដែលតុលាការជាន់ខ្ពស់ ពិនិត្យមើលការចោទប្រកាន់ពិរុទ្ធជនយ៉ាងល្អិតល្អន់ ពិចារណាលើភស្តុតាង ដែលត្រូវបានដាក់បញ្ជូនទៅសវនាការ និងត្រូវបានយោងដល់ នៅក្នុងដំណើរការឧទ្ធរណ៍ ហើយរកឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីផ្តល់យុត្តិកម្មចំពោះការរកឃើញពិរុទ្ធភាព នៅក្នុងរឿងក្តីជាក់លាក់នោះ នឹងពុំមានការបំពានលើកតិកាសញ្ញានេះទេ។[១០៣]

៤៩. សិទ្ធិសុំឲ្យពិនិត្យការផ្តន្ទាទោសខ្លួនឡើងវិញ អាចត្រូវបានអនុវត្តដោយប្រសិទ្ធភាព ប្រសិនបើពិរុទ្ធជនមានសិទ្ធិទទួលបានសាលក្រមជាលាយលក្ខណ៍អក្សរ ដែលមានសំអាងហេតុត្រឹមត្រូវរបស់សាលាដំបូង និងយ៉ាងហោចណាស់ក៏ត្រូវបានពិនិត្យដោយសាលាឧទ្ធរណ៍ជាន់ទីមួយ ក្នុងករណីដែលច្បាប់ជាតិបង្កើតសាលាឧទ្ធរណ៍ច្រើនជាន់[១០៤] ក៏ដូចជាសិទ្ធិទទួលបានឯកសារផ្សេងៗ ដូចជាកំណត់ហេតុសវនាការ ពោលគឺរាល់ឯកសារដែលចាំបាច់ដើម្បីអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍ឱ្យមានប្រសិទ្ធភាព។[១០៥] ប្រសិទ្ធភាពនៃសិទ្ធិនេះក៏ត្រូវបានធ្វើឲ្យខូចខាតផងដែរ ពោលគឺមាត្រា១៥ កថាខ័ណ្ឌទី៥ ក៏ត្រូវបានបំពាន ប្រសិនបើការពិនិត្យឡើងវិញដោយតុលាការ

---

[១០៣] ឱ. បណ្តឹងលេខ១១៥៦/២០០៣ រវាង*Pérez Escolar និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌ៣ បណ្តឹងលេខ១៣៨៩/២០០៥ រវាងBertelli Gálvez និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៤.៥។*

[១០៤] បណ្តឹងលេខ៩០៣/១៩៩៩ រវាង *Van Hulst និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.៤ បណ្តឹងលេខ៧០៩/១៩៩៦ រវាងBailey និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.២ បណ្តឹងលេខ៦៦៣/១៩៩៥ រវាងMorrison និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៨.៥។*

[១០៥] បណ្តឹងលេខ៦៦២/១៩៩៥ រវាង*Lumley និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៥។*

ជាន់ខ្ពស់នេះ ត្រូវបានពន្យាពេល ដោយមិនត្រឹមត្រូវ ផ្ទុយនឹងកថាខ័ណ្ឌទី៣(គ) នៃបទប្បញ្ញត្តិមាត្រានេះ។[១០៦]

**៥០.** ប្រព័ន្ធនៃការពិនិត្យឡើងវិញដោយមានការត្រួតពិនិត្យពីថ្នាក់លើ ដែលអនុវត្តតែចំពោះការកាត់ទោស ហើយទោសនេះត្រូវបានចាប់ផ្តើមអនុវត្តហើយ មិនបំពេញតាមលក្ខខណ្ឌតំរូវនៃមាត្រា១៤ កថាខ័ណ្ឌទី៥ ទេ ដោយមិនគិតថាការពិនិត្យឡើងវិញនេះ អាចត្រូវបានស្នើសុំដោយពិរុទ្ធជន ឬអាស្រ័យលើអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រម ឬព្រះរាជអាជ្ញា។[១០៧]

**៥១.** សិទ្ធិប្តឹងឧទ្ធរណ៍មានសារៈសំខាន់ជាពិសេសក្នុងករណីទោសប្រហារជីវិត។ ការបដិសេធមិនផ្តល់ជំនួយផ្នែកច្បាប់ ដោយឥតបង់ថ្លៃ ដោយតុលាការក្នុងការពិនិត្យឡើងវិញនូវការកាត់ទោសប្រហារជីវិតដល់ពិរុទ្ធជនក្រីក្រ មិនត្រឹមតែបំពានលើមាត្រា១៤ កថាខ័ណ្ឌទី៣(ឃ) ប៉ុណ្ណោះទេ ប៉ុន្តែទន្ទឹមគ្នានោះ ក៏បំពានលើមាត្រា១៤

[១០៦] បណ្តឹងលេខ៨៤៥/១៩៩៨ រវាង*Kennedy*និងប្រទេសទ្រីនីដាតនិងតុបាហ្គោ កថាខ័ណ្ឌទី៧.៥ *បណ្តឹងលេខ៨១៨/១៩៩៨ រវាងSextus និង ប្រទេសទ្រីនីដាតនិងតុបាហ្គោ កថាខ័ណ្ឌទី៧.៣ បណ្តឹងលេខ៧៥០/១៩៩៧ រវាងDaley និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៤ បណ្តឹងលេខ៦៦៥/១៩៩៥ រវាងBrown and Parish និង ប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៣ បណ្តឹងលេខ៧៥០/១៩៩៧ រវាងDaley និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៩.៥ បណ្តឹងលេខ៦១៤/១៩៩៥ រវាងThomas និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៩.៥ និង បណ្តឹងលេខ៥៩០/១៩៩៤ រវាងBennet និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី១០.៥។*

[១០៧] បណ្តឹងលេខ១១០០/២០០២រវាង*Bandajevsky*និងប្រទេសបេលឡារូស កថាខ័ណ្ឌទី១០.១៣ *បណ្តឹងលេខ៨៣៦/១៩៩៨ រវាងGelazauskas និងប្រទេសលីទុយអានី កាថាខ័ណ្ឌទី៧.២។*

កថាខ័ណ្ឌទី៥ ផងដែរ ដោយសារនៅក្នុងករណីបែបនេះ ការបដិសេធផ្តល់ជំនួយផ្នែកច្បាប់ដោយឥតបង់ថ្លៃ ក្នុងបណ្តឹងសាទុក្ខ ជាការប្រានចោលដ៏មានប្រសិទ្ធភាពដល់ការពិនិត្យឡើងវិញនូវការផ្តន្ទាទោស និងការកាត់ទោសឱ្យមានប្រសិទ្ធភាព ដោយតុលាការជាន់ខ្ពស់។[១០៨] សិទ្ធិសុំឲ្យពិនិត្យលើការផ្តន្ទាទោសខ្លួនឡើងវិញ ក៏ត្រូវបានបំពានផងដែរប្រសិនបើជនជាប់ចោទពុំត្រូវបានជូនដំណឹងអំពីចេតនានៃមេធាវីរបស់ខ្លួន ក្នុងការមិនដាក់អំណះអំណាងណាមួយទៅតុលាការ អាស្រ័យហេតុនេះ ធ្វើឱ្យជនជាប់ចោទបាត់បង់ឱកាសក្នុងការស្វែងរកតំណាងផ្លូវច្បាប់ផ្សេងទៀតដើម្បីឲ្យពួកគាត់អាចបង្ហាញកង្វល់នានារបស់ខ្លួន នៅសាលាឧទ្ធរណ៍នោះ។[១០៩]

[១០៨] បណ្តឹងលេខ៥៥៤/១៩៩៣ រវាង*LaVande និងប្រទេសទ្រីនីដាតនិងតូបាហ្គោ កថាខ័ណ្ឌទី ៥.៨*។

[១០៩] *សូមមើលបណ្តឹងលេខ៧៥០/១៩៩៧ រវាងDaley និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៥*
*បណ្តឹងលេខ៦៨០/១៩៩៦ រវាងGallimore និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៤*
*បណ្តឹងលេខ៦៦៨/១៩៩៥ រវាងSmith and Stewart និងប្រទេសចាម៉ៃកា កថាខ័ណ្ឌទី៧.៣*
*និងក៏សូមមើលផងដែរ*
*បណ្តឹងលេខ៩២៨/២០០០ រវាង Sooklal និងប្រទេសទ្រីនីដាតនិងតុបាហ្គោ* កថាខ័ណ្ឌទី *៤.១០*

## VIII. សំណងជម្ងឺចិត្តក្នុងករណីយុត្តិនិសេធ

**៥២.** យោងតាមកថាខ័ណ្ឌទី៦ មាត្រា១៤ នៃកតិកាសញ្ញានេះ សំណងតាមផ្លូវច្បាប់ ត្រូវផ្តល់ជូនជនណាដែលត្រូវបានផ្តន្ទាទោស ពីបទព្រហ្មទណ្ឌដោយសេចក្តីសម្រេចស្ថាពរ ហើយបានទទួលរង ទណ្ឌកម្មនេះ តាមរយៈការផ្តន្ទាទោសបែបនេះ ប្រសិនបើការផ្តន្ទាទោសនេះ ត្រូវបានបដិសេធនៅពេលក្រោយមក ឬបុគ្គលនោះត្រូវបានលើកលែងទោសដោយហេតុថា អង្គហេតុថ្មី ឬអង្គហេតុដែលទើបរកឃើញថ្មីបញ្ជាក់យ៉ាងច្បាស់ថា មានយុត្តិនិសេធ។[១១០] ជាការចាំបាច់ណាស់ ដែលរដ្ឋភាគីអនុម័តច្បាប់ដែលធានាថា សំណងតាមផ្លូវច្បាប់ដូចបានតំរូវដោយបទប្បញ្ញត្តិនេះ អាចត្រូវបានទូទាត់ជូនដោយពិតប្រាកដ ហើយថាការទូទាត់សងនេះ ត្រូវបានធ្វើនៅក្នុងរយៈពេលដ៏សមហេតុផលមួយ។

**៥៣.** ការធានាការពារនេះពុំអនុវត្តនោះទេ ប្រសិនបើមានភស្តុតាងបង្ហាញថាជនជាប់ចោទ រួមចំណែកទាំងស្រុង ឬដោយអន្លើ ចំពោះការមិនបើកបង្ហាញអង្គហេតុថ្មីបែបនោះឲ្យទាន់ពេលវេលា។ នៅក្នុងករណីបែបនេះ រដ្ឋមានបន្ទុកបង្ហាញភស្តុតាង។ លើសពីនេះ ពុំមានការផ្តល់សំណងតាមផ្លូវច្បាប់នោះទេ ប្រសិនបើការផ្តន្ទាទោស

---

[១១០] បណ្តឹងលេខ៩៦៣/២០០១ រវាង*Uebergang និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៤.២*
*បណ្តឹងលេខ៨៨០/១៩៩៩ រវាងIrving និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៨.៣*
*បណ្តឹងលេខ៤០៨/១៩៩០ រវាងW.J.H. និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.៣។*

នេះ ត្រូវបានទុកជាមោឃៈ ដោយសាលាឧទ្ធរណ៍ ឪ.មុនពេលសាលក្រមចូលជាស្ថាពរ[១១១] ឬត្រូវបានលើកលែងទោសដោយមូលហេតុមនុស្សធម៌ ឬតាមអំណាចឆន្ទានុសិទ្ធិ ឬដោយហេតុផលនៃការពិចារណាលើសមធម៌ ដោយពុំសំដៅថា មានយុត្តិនិសេធនោះទេ។[១១២]

[១១១] បណ្តឹងលេខ*៨៨០/១៩៩៩ រវាងIrving និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៨.៤ និងបណ្តឹងលេខ៨៦៨/១៩៩៩ រវាងWilson និងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៦.៦។*

[១១២] បណ្តឹងលេខ៨៩១/១៩៨១ រវាង*Muhonen និងប្រទេសហ្វាំងឡង់ កថាខ័ណ្ឌទី១១.២។*

## IX. ទ្វេទណ្ឌភាព

**៥៤.** មាត្រា១៤ កថាខ័ណ្ឌទី៧ នៃកតិកាសញ្ញានេះចែងថាគ្មានជនណាម្នាក់ត្រូវយកមកកាត់ទោស ឬផ្តន្ទាទោសម្តងទៀតចំពោះបទល្មើសដែលខ្លួនត្រូវបានផ្តន្ទាទោសជាស្ថាពរ ឬត្រូវបានសម្រេចឲ្យរួចខ្លួន ស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗនោះទេ។ មាត្រានេះ តំណាងឱ្យគោលការណ៍នៃទ្វេទណ្ឌភាព។ បទប្បញ្ញត្តនេះហាមឃាត់ការយកបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោស ឬសម្រេចឲ្យរួចខ្លួនពីបទល្មើសជាក់លាក់ណាមួយហើយនោះ មកជំនុំជម្រះជាថ្មីម្តងទៀត នៅចំពោះមុខតុលាការដដែល ឬសាលាជម្រះក្តីមួយផ្សេងទៀត ចំពោះបទល្មើសដដែលនោះទេ។ ហេតុដូច្នោះ ជាឧទាហរណ៍ បុគ្គលម្នាក់ត្រូវបានសម្រេចឲ្យរួចខ្លួនដោយតុលាការស៊ីវិល ពុំអាចត្រូវបានជំនុំជម្រះម្តងទៀត ចំពោះបទល្មើសដដែល ដោយតុលាការយោធា ឬតុលាការពិសេសណាមួយនោះទេ។ មាត្រា១៤ កថាខ័ណ្ឌទី៧ ពុំហាមឃាត់ការជំនុំជម្រះឡើងវិញនៃបុគ្គល ដែលត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ តាមការស្នើសុំរបស់បុគ្គលនោះឡើយ ប៉ុន្តែហាមឃាត់ចំពោះការផ្តន្ទាទោសជាលើកទីពីរ។

**៥៥.** ការដាក់ទណ្ឌកម្ម ម្តងហើយម្តងទៀត លើអ្នកជំទាស់តាមសម្បជញ្ញៈចំពោះការមិនគោរពតាមបទបញ្ជា ម្តងហើយម្តងទៀត

ឲ្យចូលបម្រើក្នុងយោធា អាចចាត់ទុកជាការដាក់ទណ្ឌកម្មចំពោះបទល្មើសដដែល ប្រសិនបើការបដិសេធជាបន្តបន្ទាប់បែបនោះត្រូវបានធ្វើឡើងដោយផ្អែកលើមូលហេតុសម្បជញ្ញៈដដែល។[១១៣]

**៥៦.** ការហាមឃាត់នៃមាត្រា១៤ កថាខ័ណ្ឌទី៧ ពុំចោទជាបញ្ហានោះទេ ប្រសិនបើតុលាការជាន់ខ្ពស់ បដិសេធការផ្តន្ទាទោសនេះ ហើយបង្គាប់ឲ្យជំនុំជម្រះឡើងវិញ។[១១៤] លើសពីនេះទៅទៀត បទប្បញ្ញត្តិនេះ ពុំហាមឃាត់ការចាប់ផ្តើមជាថ្មីនៃការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដែលត្រូវបានធ្វើយុត្តិកម្ម ដោយកាលៈទេសៈពិសេសណាមួយ ដូចជាការរកឃើញភស្តុតាងថ្មីដែលរកមិនបាន ឬមិនបានដឹង កាលពីពេលដែលសម្រេចឲ្យរួចខ្លួន។

**៥៧.** តាមអត្ថន័យនៃមាត្រា១៤ នៃកតិកាសញ្ញានេះ ការធានាការពារនេះ អនុវត្តតែចំពោះបទល្មើសព្រហ្មទណ្ឌប៉ុណ្ណោះ និងមិនអនុវត្តចំពោះវិធានការវិន័យ ដែលនឹងក្លាយទៅជាការដាក់ទណ្ឌកម្មសំរាប់បទល្មើសព្រហ្មទណ្ឌនោះទេ។[១១៥] លើសពីនេះ បទប្បញ្ញត្តិនេះពុំធានាការពារគោលការណ៍*ទ្វេទណ្ឌភាព* ទាក់ទិននឹងយុត្តាធិ

---

[១១៣] សូមមើល ក្រុមការងារអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្ត, សេចក្តីផ្តល់មតិលេខ៣៦/១៩៩៩ សំរាប់ប្រទេសទួរគី, E./CN.4/2001/14/Add. 1, កថាខ័ណ្ឌទី៩ និងសេចក្តីផ្តល់មតិលេខ២៤/២០០៣ សំរាប់ប្រទេសអ៊ីស្រាអែល, E/CN.4/2005/6/Add. 1, កថាខ័ណ្ឌទី៣០។

[១១៤] បណ្តឹងលេខ២៧៧/១៩៨៨ រវាង *Terán Jijón និងប្រទេសអេក្វាទ័រ កថាខ័ណ្ឌទី៥.៤។*

[១១៥] បណ្តឹងលេខ១០០១/២០០១ រវាង *Gerardus Strik និងប្រទេសហូឡង់ កថាខ័ណ្ឌទី៧.៣។*

ការជាតិ នៃរដ្ឋពីរ ឬច្រើននោះទេ។[១១៦] ទោះជាដូច្នោះក៏ដោយ ការបកស្រាយនេះ ពុំគួរធ្វើឲ្យអន្តរាយដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋនានា ដើម្បីទប់ស្កាត់មិនឱ្យមានការជំនុំជម្រះឡើងវិញ ចំពោះបទល្មើសព្រហ្មទណ្ឌដដែល តាមរយៈអនុសញ្ញាអន្តរជាតិនានានោះទេ។[១១៧]

[១១៦] បណ្តឹងលេខ៦៩២/១៩៩៦ រវាង*A.R.J និងប្រទេសអូស្ត្រាលី កថាខ័ណ្ឌទី៦.៤*
*បណ្តឹងលេខ២០៤/១៩៨៦ រវាងA.P. និងប្រទេសអ៊ីតាលី កថាខ័ណ្ឌទី៧.៣។*

[១១៧] សូមមើលឧទា. លក្ខន្តិកៈទីក្រុមរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា២០ កថាខ័ណ្ឌទី៣

## X. ទំនាក់ទំនងរវាងមាត្រា១៤ ជាមួយនឹងបទប្បញ្ញត្តិផ្សេងៗទៀត នៃកតិកាសញ្ញានេះ

៥៨. ជាបណ្តុំនៃការធានាការពារតាមនីតិវិធី មាត្រា១៤ នៃកតិកាសញ្ញានេះ ជានិច្ចកាលដើរតួរយ៉ាងសំខាន់ ក្នុងការអនុវត្តការធានាការពារសំខាន់ៗបន្ថែមទៀតនៃកតិកាសញ្ញានេះ ដែលត្រូវយកទៅពិចារណានៅក្នុងបរិបទនៃការសម្រេចពីការចោទប្រកាន់ខាងព្រហ្មទណ្ឌ ព្រមទាំងការកំណត់ពីសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គល នៅក្នុងបណ្តឹងតាមផ្លូវច្បាប់។ តាមន័យនីតិវិធី ទំនាក់ទំនងជាមួយសិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធភាព ដែលបានចែងក្រោមមាត្រា២ កថាខ័ណ្ឌទី៣ នៃកតិកាសញ្ញានេះ ក៏មានការពាក់ព័ន្ធដែរ។ ជាទូទៅ គេត្រូវការគោរពបទប្បញ្ញត្តិនេះ នៅពេលណាដែលការធានាការពារណាមួយនៃមាត្រា១៤ ត្រូវបានបំពាន។[១១៨] ទោះជាដូច្នោះក៏ដោយ ទាក់ទិននឹងសិទ្ធិសុំឲ្យពិនិត្យឡើងវិញនូវការផ្តន្ទាទោស និងការកាត់ទោសដោយតុលាការជាន់ខ្ពស់ មាត្រា១៤ កថាខ័ណ្ឌទី៥ នៃកតិកាសញ្ញានេះ គឺជា*ច្បាប់ពិសេស* ទាក់ទងទៅនឹងមាត្រា២ កថាខ័ណ្ឌទី៣ នៅពេលដែលសំអាងដល់សិទ្ធិទទួលបានការជម្រះក្តីដោយតុលាការថ្នាក់ឧទ្ធរណ៍។[១១៩]

---

[១១៨] ឧទាហរណ៍ បណ្តឹងលេខ១០៣៣/២០០១ រវាង*Singarasa និងប្រទេសស្រីលង្កា កថាខ័ណ្ឌទី៧.៤ និងបណ្តឹងលេខ៨២៣/១៩៩៨ រវាងCzernin និងសាធារណរដ្ឋឆែក កថាខ័ណ្ឌទី៧.៥។*

[១១៩] បណ្តឹងលេខ១០៧៣/២០០២ រវាង*Terrón និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៦.៦។*

**៥៩.** នៅក្នុងករណីនៃការជំនុំជម្រះ ដែលនាំដល់ការដាក់ទោសប្រហារជីវិត ការគោរពយ៉ាងម៉ឺងម៉ាត់នៃការធានាការពារពីជំនុំជម្រះដោយយុត្តិធម៌ជាបញ្ហាសំខាន់ខ្លាំងណាស់។ ការកាត់ទោសប្រហារជីវិតដោយការជំនុំជម្រះជាស្ថាពរមួយ ដែលពុំគោរពបទប្បញ្ញត្តិនានារបស់មាត្រា១៤ នៃកតិកាសញ្ញានេះ គឺជាការរំលោភបំពានលើសិទ្ធិរស់រានមានជីវិត (មាត្រា៦ នៃកតិកាសញ្ញានេះ)។[១២០]

**៦០.** ប្រព្រឹត្តមិនគប្បីលើជនជាប់ចោទពីបទព្រហ្មទណ្ឌ និងបង្ខំជនជាប់ចោទឲ្យសារភាព ឬចុះហត្ថលេខាលើចម្លើយសារភាពដោយការកៀបសង្កត់ឱ្យទទួលយកពិរុទ្ធភាព គឺជាការបំពានលើមាត្រា៧ នៃអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប និងមាត្រា១៤ កថាខ័ណ្ឌទី៣(ឆ) នៃកតិកាសញ្ញានេះ ដែលហាមឃាត់ការបង្ខិតបង្ខំឲ្យធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពពីពិរុទ្ធនោះទេ។[១២១]

---

[១២០] ឧ. បណ្តឹងលេខ១០៨៤/២០០២ រវាង*Shakurova និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៨.៥ (ការបំពានលើមាត្រា១៤ កថាខ័ណ្ឌទី១ និងទី៣ (ខ) (ឃ) និង(ឆ))*

*បណ្តឹងលេខ៩១៥/២000 រវាងRuzmetov និងប្រទេសអ៊ុយបេគីស្ថាន កថាខ័ណ្ឌទី៧.៦ (ការបំពានលើមាត្រា១៤ កថាខ័ណ្ឌទី១ ទី២ និងទី៣ (ខ) (ឃ) (ង) និង(ឆ))*

*បណ្តឹងលេខ៩១៣/២000 រវាង Chan និងប្រទេសហ្គីយាណា កថាខ័ណ្ឌទី៥.៤ (ការបំពានលើមាត្រា១៤ កថាខ័ណ្ឌទី៣ (ខ) និង(ឃ))*

*បណ្តឹងលេខ១១៦៧/២០០៣ រវាងRayos និងប្រទេសហ្វីលីពីន កថាខ័ណ្ឌទី៧.៣ (ការបំពានលើមាត្រា១៤ កថាខ័ណ្ឌទី៣ (ខ))។*

[១២១] បណ្តឹងលេខ១០៨៤/២០០២ រវាង*Shakurova និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៨.២*

*បណ្តឹងលេខ៩១៥/២000រវាងRuzmetov និងប្រទេសអ៊ុយបេគីស្ថាន កថាខ័ណ្ឌទី៧.២និងកថាខ័ណ្ឌទី៧.៣*

*បណ្តឹងលេខ១០៨២/២០០១ រវាងBoimurodov និងប្រទេសតាក់ជីគីស្ថាន កថាខ័ណ្ឌទី៧.២ និងបណ្តឹងផ្សេងៗជាច្រើនទៀត។ អំពីការហាមឃាត់ទទួលយកភស្តុតាងដែលបំពានលើមាត្រា៧ សូមមើលកថាខ័ណ្ឌទី៦ និងទី៤១ ខាងលើ។*

**៦១.** ការហាមឃាត់ចំពោះការពន្យាពេលជំនុំជម្រះ ដោយមិនត្រឹមត្រូវដូចមានចែងក្នុងមាត្រា៩ កថាខ័ណ្ឌទី៣ និងមាត្រា១៤ កថាខ័ណ្ឌទី៣(គ) នៃកតិកាសញ្ញានេះអាចត្រូវបានបំពានដូចគ្នា ប្រសិនបើជន ដែលជាប់សង្ស័យពីបទល្មើសព្រហ្មទណ្ឌ និងត្រូវបានឃុំខ្លួនដោយផ្អែកតាមមាត្រា៩ នៃកតិកាសញ្ញានេះ ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ ប៉ុន្តែមិនត្រូវបាននាំយកទៅជំនុំជម្រះនោះ។[១២២]

**៦២.** ការធានាការពារតាមនីតិវិធីនៃមាត្រា១៣ នៃកតិកាសញ្ញានេះ មានបញ្ចូលសញ្ញាណនៃនីតិវិធីត្រឹមត្រូវ ក៏បានឆ្លុះបញ្ចាំងផងដែរក្នុងមាត្រា១៤[១២៣] ហើយហេតុដូច្នេះ គួរត្រូវបានបកស្រាយតាមស្មារតីនៃបទប្បញ្ញត្តិមាត្រា១៤នេះ។ការធានាការពារគោលការណ៍នៃភាពស្មើគ្នារបស់បុគ្គលគ្រប់រូប នៅចំពោះមុខតុលាការ និងសាលាជម្រះក្តីដូចបានតំកល់ទុកក្នុងមាត្រា១៤ កថាខ័ណ្ឌទី១ និងគោលការណ៍អនាគតិ ភាពត្រឹមត្រូវ និងសមភាពនៃភាគីក្នុងរឿងក្តីដែលមានចែងយ៉ាងច្បាស់នៅក្នុងការធានាការពារនេះ ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលច្បាប់ជាតិផ្តល់ការទុកចិត្តដល់ស្ថាប័នយុត្តាធិការមួយនូវបេសកកម្មក្នុងការសម្រេចសេចក្តីលើការ

---

[១២២] បណ្តឹងលេខ៩០៨/២០០០ រវាង *Evans និង ប្រទេសទ្រីនីដាតនិងតុបាហ្គោ កថាខ័ណ្ឌទី៦.២* *បណ្តឹងលេខ៨៣៨/១៩៩៨ រវាងHendricks និងប្រទេសហ្គីយាណា កថាខ័ណ្ឌទី៦.៣ និងបណ្តឹងជាច្រើនផ្សេងទៀត។*

[១២៣] បណ្តឹងលេខ១០៥១/២០០២ រវាង *Ahani និងប្រទេសកាណាដា កថាខ័ណ្ឌទី១០.៩។ សូមមើលផងដែរ បណ្តឹងលេខ៩៦១/២០០០ រវាងEverett និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៦.៤ (ស្តីពីការធ្វើបត្យាប័ន) និងបណ្តឹងលេខ១៤៣៨/២០០៥ រវាងTaghi Khadje និងប្រទេសហូឡង់ កថាខ័ណ្ឌទី៦.៣។*

បណ្តេញចេញពីប្រទេស ឬការធ្វើនិរទេស។[១២៤] ទោះជាដូច្នោះក្តី ការធានាការពារទាំងអស់ក្រោមមាត្រា១៤ ត្រូវយកទៅអនុវត្តក្នុង ករណីដែលការបណ្តេញចេញពីប្រទេស ប្រព្រឹត្តទៅក្រោមទម្រង់ នៃការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ឬក្នុងករណីដែលការបំពានលើបទ បញ្ញាបណ្តេញចេញ ត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ។

**៦៣.** បែបបទដែលដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវបានចាត់ការ អាចប៉ះពាល់ដល់ការអនុវត្ត និងការប្រើប្រាស់សិទ្ធិ និងការធានា ការពារនានានៃកតិកាសញ្ញាដែលមិនទាក់ទិននឹងមាត្រា១៤។ ដូច្នេះ ហើយ ជាឧទាហរណ៍ ការបង្អង់ដីកាចោទប្រកាន់ជាច្រើនឆ្នាំចំពោះ បណ្តឹងបរិហារកេរ្តិ៍ប្រឆាំងនឹងអ្នកសារព័ត៌មាន ដែលបានចុះផ្សាយ អត្ថបទមួយចំនួនដោយបំពានលើមាត្រា១៤ កថាខ័ណ្ឌទី៣(គ) អាច ដាក់ជនជាប់ចោទ ឱ្យស្ថិតនៅក្នុងស្ថានភាពមួយមិនប្រាកដប្រជា និងបំភិតបំភ៉ៃ ហេតុដូច្នោះហើយ បណ្តាលឱ្យមានការប៉ះពាល់ធ្ងន់ ធ្ងរ ដែលរឹតត្បិតដោយមិនត្រឹមត្រូវលើការអនុវត្តសិទ្ធិមានសេរីភាព ខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាននោះ (មាត្រា១៩ នៃ កតិកាសញ្ញានេះ)។[១២៥] ដូចគ្នាផងដែរ ការពន្យាពេលនៃដំណើរការ នីតិវិធីព្រហ្មទណ្ឌអស់ជាច្រើនឆ្នាំ ដោយល្មើសនឹងមាត្រា១៤ កថាខ័ណ្ឌទី៣(គ) អាចបំពានលើសិទ្ធិរបស់បុគ្គល ក្នុងការចាកចេញ ពីប្រទេសកំណើត ដូចបានចែងក្នុងមាត្រា១២ កថាខ័ណ្ឌទី២ នៃ

[១២៤]សូមមើលបណ្តឹងលេខ៩៦១/២០០០ រវាង*Everett និងប្រទេសអេស្ប៉ាញ កថាខ័ណ្ឌទី៦.៤។*

[១២៥] បណ្តឹងលេខ៩០៩/២០០០ រវាង*Mujuwana Kankanamge និងប្រទេសស្រីលង្កា កថាខ័ណ្ឌទី៩.៤។*

កតិកាសញ្ញានេះ ដោយសារតែជនជាប់ចោទ ត្រូវតែស្ថិតនៅក្នុងប្រទេសនោះរហូតដរាបណាដំណើការរឿងក្តីនោះនៅមិនចប់។[១២៦]

**៦៤.** ទាក់ទិននឹងសិទ្ធិទទួលបានសេវាសាធារណៈក្នុងន័យទូទៅនៃសមភាព ដូចមានចែងក្នុងមាត្រា២៥(គ) នៃកតិកាសញ្ញានេះ ការបណ្តេញចៅក្រមពីមុខដំណែង ដោយបំពានលើបទប្បញ្ញត្តិនេះ អាចមានន័យស្មើនឹងការបំពានលើការធានាការពារនេះដែរ បើយើងអានដោយភ្ជាប់ទៅនឹងមាត្រា១៤ កថាខ័ណ្ឌទី១ ដែលចែងពីឯករាជភាពរបស់តុលាការ។[១២៧]

**៦៥.** ច្បាប់នីតិវិធី ឬការអនុវត្តច្បាប់ទាំងនោះ ដែលធ្វើឲ្យមានការបែងចែក ដោយផ្អែកលើលក្ខណៈ វិនិច្ឆ័យណាមួយ ដូចបានរៀបរាប់ជាបញ្ជីក្នុងមាត្រា២ កថាខ័ណ្ឌទី១ ឬមាត្រា២៦ ឬការមិនចាត់ទុក សិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ស្របតាមមាត្រា៣ ដើម្បីទទួលបានការធានាការពារនានា ដូចមាន ចែងក្នុងមាត្រា១៤ នៃកតិកាសញ្ញានេះ មិនគ្រាន់តែបំពានលើលក្ខខណ្ឌតំរូវនៃកថាខ័ណ្ឌទី១ នៃបទ ប្បញ្ញត្តិនេះ ដែលថា"បុគ្គលគ្រប់រូប ត្រូវតែស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី" នោះទេ តែថែមទាំងអាចមានន័យស្មើនឹងការរើសអើងផងដែរ។[១២៨]

៚*៛

[១២៦] បណ្តឹងលេខ២៦៣/១៩៨៧ រវាង*Gonzales del Rio* និងប្រទេសប៉េរូ កថាខ័ណ្ឌទី៥.២ និង៥.៣

[១២៧] បណ្តឹងលេខ៩៣៣/២០០០ រវាង*Mundyo Busyo et al.*និងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ កថាខ័ណ្ឌទី៥.២

*បណ្តឹងលេខ៨១៤/១៩៩៨ រវាងPastukhov និងប្រទេសបេលឡារូស កថាខ័ណ្ឌទី៧.៣។*

[១២៨] បណ្តឹងលេខ២០២/១៩៨៦ រវាង*Ato del Avellanal* និងប្រទេសប៉េរូ កថាខ័ណ្ឌទី១០.១ និង១០.២។